ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយ
# ស្តីពី
# ការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា

រៀបចំដោយក្រុមប្រឹក្សាជាតិគាំពារសង្គម
ខែឧសភា ឆ្នាំ២០២៦

# មាតិកា

បុព្វកថា ........ I

១. សេចក្តីផ្តើម ........ ១

១.១. ស្ថានភាពទូទៅនៃបញ្ហាជនអនាថានៅកម្ពុជា ........ ១

១.២. ស្ថានភាពបញ្ហាជនអនាថា និងបទពិសោធថ្នាក់តំបន់ ........ ៣

២. ចក្ខុវិស័យ ........ ៥

៣. គោលបំណង គោលដៅ និងគោលការណ៍ ........ ៥

៤. យុទ្ធសាស្ត្រ ........ ៧

៤.១. អភិវឌ្ឍយន្តការកំណត់អត្តសញ្ញាណ និងគ្រប់គ្រងទិន្នន័យជនអនាថា ........ ៧

៤.២. ពង្រឹងអភិបាលកិច្ច ភាពជាដៃគូ និងយន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូ ........ ៨

៤.៣. រៀបចំកន្លែងសំចតសុវត្ថិភាព និងមជ្ឈមណ្ឌលឯកទេសសង្គមកិច្ច ........ ៩

៤.៤. អភិវឌ្ឍយន្តការចាំបាច់សម្រាប់ការទទួលបានសេវាបំពេញបន្ថែមនិងអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គម ........ ១១

៤.៤.១. អភិវឌ្ឍយន្តការចាំបាច់សម្រាប់ការបញ្ជូនបន្តទៅទទួលបានសេវាបំពេញបន្ថែម ........ ១១

៤.៤.២. លើកកម្ពស់ការទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គម ........ ១២

៤.៥. អភិវឌ្ឍយន្តការសមាហរណកម្មជនអនាថាទៅក្នុងសហគមន៍វិញ ........ ១៣

៤.៦. លើកកម្ពស់ការយល់ដឹងដល់សហគមន៍ ........ ១៤

៥. យន្តការជំរុញការអនុវត្តគោលនយោបាយ ........ ១៥

៥.១. ការអភិវឌ្ឍក្របខណ្ឌគតិយុត្ត ........ ១៥

៥.២. យន្តការស្ថាប័ន និងយន្តការសម្របសម្រួលក្នុងការអនុវត្តគោលនយោបាយ ........ ១៦

៥.៣. ការបណ្តុះបណ្តាលធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ........ ១៧

៥.៣.១. ការបណ្តុះបណ្តាលធនធានមនុស្ស ........ ១៧

៥.៣.២. ធនធានហិរញ្ញវត្ថុ ........ ១៨

៥.៤. ការរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តគោលនយោបាយ ........ ១៨

៦. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ........ ១៩

៧. សេចក្តីសន្និដ្ឋាន ........ ២០

៨. សន្ទានុក្រម ........ ២១

# បុព្វកថា

ក្នុងរយៈពេលជាង ៣ ទសវត្សរ៍នេះ រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន គួរជាទីមោទនៈ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដែលធ្វើឱ្យសុខុមាលភាពប្រជាជនប្រសើរឡើងជាបន្តបន្ទាប់។ ដើម្បីសម្រេចបានចក្ខុវិស័យរយៈពេលវែង ក្នុងការប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០, រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា តាមរយៈការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ នៅតែបន្តផ្តោតលើការលើកកម្ពស់ការអភិវឌ្ឍមូលធនមនុស្ស ជាគោលដៅអាទិភាពទី១ សម្រាប់ការអភិវឌ្ឍប្រទេសជាតិ។ ព្រមជាមួយគ្នានេះ រាជរដ្ឋាភិបាលបាន និងកំពុងបន្តអភិវឌ្ឍ និងអនុវត្តគោលនយោបាយនានា សំដៅលើកកម្ពស់សុខុមាលភាពពលរដ្ឋប្រកបដោយចីរភាព សមធម៌ និងបរិយាបន្ន ដោយឈរលើស្មារតី "**មិនបោះបង់ពលរដ្ឋណាម្នាក់**"។

ទន្ទឹមនឹងសមិទ្ធផល និងកម្មវិធីគោលនយោបាយប្រកបដោយចក្ខុវិស័យនេះ ក្រុមពលរដ្ឋងាយរងគ្រោះមួយចំនួន នៅមិនទាន់ទទួលបានការគាំពារ និងសេវាសង្គមកិច្ចសមស្រប តាមរយៈយន្តការដែលមានស្រាប់នៅឡើយ ក្នុងនោះក៏រួមមានជនអនាថាផងដែរ។ ជនអនាថា សំដៅដល់ជនទីទ័លក្រ, គ្មានជម្រកពិតប្រាកដ, គ្មានទីពឹង, តែលតោលនៅតាមទីសាធារណៈ, ចំណាកស្រុកពីកន្លែងមួយទៅកន្លែងមួយ គ្មានមុខរបរពិតប្រាកដ, ឬប្រកបរបរបែបអនាធិបតេយ្យតាមដងផ្លូវ ឬទីសាធារណៈ ដែលគ្មានទីតាំងច្បាស់លាស់ ដែលត្រូវបានប្រទះឃើញជាហូរហែ នៅតាមតំបន់ប្រជុំជន និងក្នុងអំឡុងពិធីបុណ្យធំៗ។ ជនអនាថាមួយចំនួនបានធ្លាក់ខ្លួនប្រព្រឹត្តអំពើអបាយមុខ, រងនូវការកេងប្រវ័ញ្ចកម្លាំងពលកម្ម, និងផ្លូវភេទ និងក្លាយជាជនរងគ្រោះដោយការសេពគ្រឿងញៀនទៀតផង។ ឫសគល់ និងបញ្ហាប្រឈមនៃបញ្ហាជនអនាថា រួមមានកត្តាមេខ្យល់, កង្វះខាតយន្តការគ្រប់គ្រងមានប្រសិទ្ធភាព, ភាពក្រីក្រ, ភាពគ្មានការងារធ្វើ ឬមិនមានការងារជាប់លាប់, កង្វះសមត្ថភាពវិជ្ជាជីវៈ, ការជ្រើសរើសរស់នៅតាមទីសាធារណៈដោយស្ម័គ្រចិត្ត, ការធ្វើចំណាកស្រុក, បញ្ហាសុខភាព, បញ្ហាគ្រួសារ, អំពើហិង្សា, និងការរើសអើងជាដើម។ កន្លងមក, វិធានការមួយចំនួនដែលក្រសួង-ស្ថាប័នពាក់ព័ន្ធបានដាក់ចេញសំដៅដោះស្រាយបញ្ហាជនអនាថា នៅមិនទាន់មានលក្ខណៈជាយុទ្ធសាស្ត្រ គ្រប់ជ្រុងជ្រោយ ប្រទាក់ក្រឡា និងមិនទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់នៅឡើយ។

ក្នុងគោលបំណងឆ្លើយតបនឹងភាពចាំបាច់ក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងជនអនាថានៅប្រទេសកម្ពុជា ក៏ដូចជាស្របតាមបទពិសោធនៃប្រទេសក្នុងតំបន់ដែលមានសមានគតិភាពជាមួយនឹងស្ថានភាពប្រទេសកម្ពុជា, រាជរដ្ឋាភិបាលសម្រេចដាក់ចេញ "**គោលនយោបាយស្តីពីការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា**" ដែលជាក្របខណ្ឌរួម ចង្អុលបង្ហាញនូវដំណោះស្រាយជាយុទ្ធសាស្ត្រ និងយន្តការសំខាន់ៗ សម្រាប់តម្រង់ទិសដល់ភាគីពាក់ព័ន្ធគ្រប់កម្រិតលើការងារគ្រប់គ្រង និងដោះស្រាយបញ្ហាជនអនាថាទូទាំងប្រទេស ឱ្យមានលក្ខណៈជាប្រព័ន្ធប្រកបដោយសង្គតិភាព សំដៅផ្តល់ការគាំពារ និងផ្តល់សេវាសង្គមកិច្ចដល់ជនអនាថា ដើម្បីលើកកម្ពស់សុខុមាលភាព និងស្ថានភាពរស់នៅរបស់ជនអនាថាឱ្យប្រសើរឡើង។ តាមរយៈការដាក់ចេញនូវគោលនយោបាយនេះ សុខុមាលភាពពលរដ្ឋងាយរងគ្រោះ នឹងត្រូវបានលើកកម្ពស់មួយកម្រិតទៀត

តាមរយៈការទទួលបានការការពារទល់នឹងហានិភ័យផ្សេងៗ ដែលនឹងផ្តល់កម្មវិបាកវិជ្ជមាន ក្នុងការរួមចំណែកកសាងសេដ្ឋកិច្ច និងសង្គមជាតិ អនុលោមតាមគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។ ដើម្បីជានាបាននូវប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយនេះ គោលការណ៍សំខាន់ៗត្រូវបានដាក់ចេញ រួមមាន៖ (១)សមភាព និងសមធម៌, (២) បរិយាបន្នសង្គម, (៣) សិទ្ធិបុគ្គលជាមូលដ្ឋាន, (៤) សេចក្តីថ្លៃថ្នូរ, និង (៥) សុវត្ថិភាព។

ការដាក់ចេញនូវគោលនយោបាយនេះ ជាចំណុចចាប់ផ្តើមប៉ុណ្ណោះ សម្រាប់ការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថាជាប្រព័ន្ធ និងលក្ខណៈជាយុទ្ធសាស្ត្រ ដែលការអនុវត្តជាក់ស្តែងទាមទារការចូលរួម និងកិច្ចសហការខ្ពស់ពីគ្រប់ក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ ដោយសារការងារគ្រប់គ្រង និងដោះស្រាយបញ្ហាជនអនាថា មានភាពស្មុគស្មាញ និងមានលក្ខណៈអន្តរវិស័យ និងអន្តរស្ថាប័ន។ ឯកសារគោលនយោបាយនេះ ត្រូវបានចាត់ទុកជាឯកសាររស់ ដែលនឹងត្រូវពិនិត្យវាយតម្លៃ និងកែសម្រួលជាប្រចាំ ដើម្បីដាក់ចេញនូវវិធានការនានាដែលឆ្លើយតបនឹងបរិការណ៍ជាក់ស្តែង និងស្របតាមការវិវត្តរបស់សង្គមជាតិ ក្នុងន័យធានាបាននូវវឌ្ឍនភាព សង្គតិភាព និងប្រសិទ្ធភាពការងារ។ ក្នុងន័យនេះ, ខ្ញុំសូមឱ្យក្រសួង-ស្ថាប័នទទួលបន្ទុកអនុវត្តវិធានការចម្បងនៃគោលនយោបាយនេះ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, វិស័យឯកជន, ដៃគូអភិវឌ្ឍន៍, អង្គការសង្គមស៊ីវិល, និងភាគីពាក់ព័ន្ធ អនុវត្ត និងសហការអនុវត្តគោលនយោបាយនេះ ក្នុងស្មារតីបុរេសកម្ម, អន្តរសកម្ម, និងការទទួលខុសត្រូវខ្ពស់ ដោយតម្កល់ឧត្តមប្រយោជន៍ជាតិ និងពលរដ្ឋកម្ពុជា ជាពិសេសជនងាយរងគ្រោះ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម, ឯកឧត្តម **ឌា សុមេធី** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា ព្រមទាំងមន្ត្រីពាក់ព័ន្ធគ្រប់កម្រិត ចំពោះកិច្ចខិតខំ ក្នុងការដឹកនាំ, សម្របសម្រួល, និងតម្រង់ទិសការរៀបចំគោលនយោបាយ រហូតសម្រេចបាននូវសមិទ្ធផលជាគោលនយោបាយប្រកបដោយយុទ្ធសាស្ត្រនេះ។

ថ្ងៃពុធ ៥ រោច ខែពិសាខ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# ១. សេចក្តីផ្តើម

ឈរលើគោលការណ៍ «មិនបោះបង់ពលរដ្ឋណាម្នាក់» រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រ កម្មវិធីគោលនយោបាយ និងកិច្ចអន្តរាគមន៍នានា ដើម្បីលើកស្ទួយជីវភាព និងសុខុមាលភាពរបស់ពលរដ្ឋ ជាពិសេសពលរដ្ឋក្រីក្រ ក្រុមជនងាយរងគ្រោះ និងពលរដ្ឋងាយរងហានិភ័យ។ យ៉ាងណាមិញ, ជនអនាថាដែលត្រូវបានចាត់ទុកថាជាក្រុមគោលដៅងាយរងគ្រោះមួយ នៅមិនទាន់ទទួលបានការគាំទ្រពេញលេញ និងមានប្រសិទ្ធភាព តាមយន្តការដែលមានស្រាប់នៅឡើយ។ បញ្ហាជនអនាថា ជាបញ្ហាចាក់ស្រេះក្នុងសង្គម, មានភាពស្មុគស្មាញ, និងជាកិច្ចការពហុវិស័យ ដែលកន្លងមកបញ្ហានេះបានបង្កឱ្យមានកម្មវិបាកអវិជ្ជមានដល់សង្គមជាតិទាំងមូល។ វត្តមានរបស់ជនអនាថាដែលស្នាក់នៅរាយប៉ាយ និងដើរសុំទាននៅតាមទីសាធារណៈ ជាពិសេសតាមទីប្រជុំជន តំបន់ទេសចរណ៍ និងក្នុងអំឡុងពិធីបុណ្យធំៗ មានផលអវិជ្ជមានដល់មុខមាត់ប្រទេសជាតិ, សេចក្តីថ្លៃថ្នូរ, សន្តិសុខសង្គម, និងសណ្តាប់ធ្នាប់សាធារណៈ ហើយជនអនាថាមួយចំនួនក៏បានក្លាយជាជនល្មើសប្រព្រឹត្តអំពើអបាយមុខពាលាអាវ៉ាសែ, ប្រព្រឹត្តអំពើជួញដូរផ្លូវភេទជាដើម និងខ្លះទៀតជាជនរងគ្រោះដោយការសេពគ្រឿងញៀនទៀតផង។ ទន្ទឹមនេះ, បញ្ហាជំងឺផ្លូវចិត្តដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន, ជំងឺវិកលចរិតវង្វេងវង្វាន់, និងជំងឺផ្លូវចិត្តដទៃទៀត ក៏បាននាំឱ្យពលរដ្ឋមួយចំនួនក្លាយជាជនវិបល្លាសស្មារតី ដែលបណ្តាលឱ្យពួកគាត់មួយចំនួនត្រូវបានសាច់ញាតិបោះបង់ចោល, ដើរតែលតោលតាមផ្លូវ និងរស់នៅគ្មានសណ្តាប់ធ្នាប់តាមទីសាធារណៈ។ លក្ខខណ្ឌនៃការរស់នៅមិនសមស្រប ធ្វើឱ្យជនអនាថាទាំងនោះជួបបញ្ហាជាច្រើននៅក្នុងជីវភាពរស់នៅ ដូចជា កង្វះការថែទាំសុខភាព ការមានជំងឺរ៉ាំរ៉ៃ ការរងអំពើហិង្សា កុមារនៅក្នុងបន្ទុកគ្រួសារមិនបានរៀនសូត្រ ឬទទួលបានការបណ្តុះបណ្តាលសមត្ថភាព កង្វះអាហារូបត្ថម្ភ ប្រឈមនឹងការកេងប្រវ័ញ្ចក្នុងទម្រង់ផ្សេងៗ ព្រមទាំងអាចធ្លាក់ខ្លួនជាជនរងគ្រោះក្នុងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ជាដើម។ កន្លងមក វិធានការមួយចំនួនដែលក្រសួង-ស្ថាប័នពាក់ព័ន្ធបានដាក់ចេញ មិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ ហើយយន្តការតាមដានត្រួតពិនិត្យការធ្វើសមាហរណកម្មជនអនាថាទៅក្នុងសហគមន៍ នៅមិនទាន់មានលក្ខណៈជាប្រព័ន្ធ ដែលជាហេតុធ្វើឱ្យជនអនាថាវិលត្រលប់មកនៅតាមដងផ្លូវ និងតាមទីសាធារណៈឡើងវិញ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលសម្រេចដាក់ចេញ “**គោលនយោបាយស្តីពីការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា**” នេះ ដើម្បីដោះស្រាយបញ្ហាជនអនាថានៅកម្ពុជា ជាលក្ខណៈយុទ្ធសាស្ត្រ និងគ្រប់ជ្រុងជ្រោយ។

## ១.១. ស្ថានភាពទូទៅនៃបញ្ហាជនអនាថានៅកម្ពុជា

ជនអនាថា សំដៅដល់ជនទីទ័លក្រ គ្មានទីជម្រកពិតប្រាកដ គ្មានទីពឹង តែលតោលនៅតាមទីសាធារណៈ ចំណាកស្រុកពីកន្លែងមួយទៅកន្លែងមួយ គ្មានមុខរបរពិតប្រាកដ ឬ ប្រកបរបរបែបអនាធិបតេយ្យតាមដងផ្លូវ ឬទីសាធារណៈដែលគ្មានទីតាំងច្បាស់លាស់ ដោយសារភាពក្រីក្រ

ការគំរាមផ្សេងៗ ឬដោយសារការកេងប្រវ័ញ្ចកម្លាំងពលកម្ម ឬផ្លូវភេទជាដើម។ ជនអនាថាត្រូវបានបែងចែកជា ៥ ប្រភេទ រួមមាន៖

១. **ជនរស់នៅអចិន្ត្រៃយ៍តាមទីសាធារណៈ៖** ជាជនមិនមានផ្ទះសម្បែង ឬជម្រកពិតប្រាកដ ចល័តពីទីតាំងមួយទៅទីតាំងមួយ ឬពីខេត្តមួយទៅខេត្តមួយ និងជាជនដែលកាត់ផ្តាច់ទំនាក់ទំនងពីគ្រួសារមករស់នៅតាមទីសាធារណៈតែម្នាក់ឯង,

២. **ជនរស់នៅជាមួយគ្រួសារ តាមទីសាធារណៈ៖** ជាជនដែលគ្មានកន្លែងស្នាក់នៅ រស់នៅទាំងគ្រួសារតាមទីសាធារណៈ ចល័តពីទីតាំងមួយទៅទីតាំងមួយ ឬពីខេត្តមួយទៅខេត្តមួយ គ្មានមុខរបរច្បាស់លាស់ ទីទ័លក្រ គ្មានទីពឹង,

៣. **ជនធ្វើការអនាធិបតេយ្យតាមទីសាធារណៈ៖** ជាជនដែលបានចំណាយពេលច្រើនធ្វើការ ឬប្រកបមុខរបរមិនច្បាស់លាស់ អនាធិបតេយ្យ តាមទីសាធារណៈ ហើយត្រលប់ទៅកន្លែងស្នាក់នៅវិញ,

៤. **ជនរងគ្រោះ ឬគ្រួសាររងគ្រោះដោយការជួញដូរ និងកេងប្រវ័ញ្ចលើកម្លាំងពលកម្ម ឬផ្លូវភេទ៖** ជាជនដែលត្រូវបានមេគ្រួសារ ឬមេខ្យល់ជួញដូរ និងកេងប្រវ័ញ្ចលើកម្លាំងពលកម្ម ឬផ្លូវភេទដើម្បីទទួលបានប្រាក់ចំណូលសម្រាប់គ្រួសារ ឬសម្រាប់មេខ្យល់ ប៉ុន្តែក្រុមនេះត្រលប់ទៅកន្លែងស្នាក់នៅវិញ ហើយការប្រកបមុខរបររបស់ក្រុមនេះធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ, និង

៥. **ជនវិបល្លាសស្មារតីដើរអនាថាតាមទីសាធារណៈ៖** ជនដែលមានវិបត្តិផ្នែកអារម្មណ៍ និងការគិតដែលកើតឡើងជាប្រចាំ និងដើរអនាថាតាមទីសាធារណៈ។

បច្ចុប្បន្ន, ជនអនាថាមានការកើនឡើងនៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសនៅតាមតំបន់ទេសចរណ៍ក្នុងអំឡុងពិធីបុណ្យធំៗ ដែលយោងតាមលទ្ធផលនៃអង្កេតបឋមរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា កាលពីឆ្នាំ២០២៤ ជនអនាថាមានចំនួនសរុបប្រមាណ ៣ ៥០០ នាក់ (ស្រី ១ ២០០ នាក់) និងជនវិបល្លាសស្មារតី មានសរុបចំនួនប្រមាណ ៣ ៨០០ នាក់ (ស្រី ១ ៥០០ នាក់)។ កន្លងមក, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, អាជ្ញាធរមូលដ្ឋាន និងក្រសួង-ស្ថាប័នពាក់ព័ន្ធ រួមទាំងអង្គការដៃគូមួយចំនួន បានអនុវត្តវិធានការដោះស្រាយនានា ប៉ុន្តែវិធានការទាំងនោះហាក់មិនទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់ និងឆ្លើយតបទៅនឹងបញ្ហានៅឡើយ ដោយសារកង្វះនូវយុទ្ធសាស្ត្រ ឬគោលនយោបាយរួម ដែលជាក់លាក់ និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ឫសគល់ (Root cause) និងបញ្ហាប្រឈមនៃការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា មានដូចខាងក្រោម៖

**ឫសគល់នៃបញ្ហាជនអនាថា៖**

- ជនអនាថាមួយចំនួនយកការសុំទានជាមុខរបរអាជីព ឬជាការងារបន្ថែម ខណៈមួយចំនួនទៀតមានទីលំនៅច្បាស់លាស់ ហើយបាន និងកំពុងទទួលអត្ថប្រយោជន៍គាំពារសង្គមពីរាជរដ្ឋាភិបាលរួចហើយ។ ក្រុមជនអនាថានេះ ភាគច្រើនតែងតែត្រលប់មកប្រកបរបរសុំទានតាមដងផ្លូវ ឬតាមទីសាធារណៈវិញ ទោះទទួលបានការគាំទ្រពីរាជរដ្ឋាភិបាល ក៏ដោយ។

- មាន "មេខ្យល់" ធ្វើការចងក្រងជនអនាថាជាក្រុម ដោយធ្វើសកម្មភាពក្រោមទម្រង់ ដូចជា ក្រុមចម្រៀងរែអង្គាសថវិកាដែលគ្មានការអនុញ្ញាត និងក្រុមកុមារ, មនុស្សវ័យចាស់, និងស្ត្រី ដើរសុំទាន និងលក់ផ្កា ឬរបស់របរបន្តិចបន្តួច តាមចំណុចភ្លើងស្តុប ដែលករណីនេះជាការជិះជាន់ កេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ស្ត្រី ជនមានពិការភាព និងមនុស្សវ័យចាស់ ដែលចាំបាច់ត្រូវ ចាត់វិធានការតឹងរ៉ឹង។
- កត្តាមួយចំនួនទៀតដែលបណ្តាលឱ្យពលរដ្ឋមួយចំនួនក្លាយជាជនអនាថា រួមមានភាពក្រីក្រ, ភាពគ្មានការងារធ្វើ ឬមិនមានការងារជាប់លាប់, កង្វះសមត្ថភាពវិជ្ជាជីវៈ, ការធ្វើចំណាកស្រុក, បញ្ហាសុខភាព, បញ្ហាគ្រួសារ, អំពើហិង្សា, និងការរើសអើងជាដើម។

**បញ្ហាប្រឈមក្នុងការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា៖**

- ការធ្វើសមាហរណកម្មជនអនាថាទៅសហគមន៍វិញកន្លងមក នៅមិនទាន់មានប្រសិទ្ធភាព ដែលបានត្រឹមដោះស្រាយបញ្ហាបណ្តោះអាសន្ន ដោយសារកត្តាកង្វះយន្តការ និងនីតិវិធី ប្រតិបត្តិ ហើយយន្តការគ្រប់គ្រង និងតាមដានត្រួតពិនិត្យមិនទាន់មានលក្ខណៈជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយ។
- ក្របខណ្ឌគោលនយោបាយ, ឬលិខិតបទដ្ឋានគតិយុត្ត ដើម្បីដោះស្រាយបញ្ហាជនអនាថា នៅ មិនទាន់មានលក្ខណៈជាយុទ្ធសាស្ត្ររួម ប្រកបដោយប្រសិទ្ធភាព និងចីរភាពនៅឡើយ។
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ មិនទាន់បានអនុវត្តតួនាទី និងភារកិច្ចបានពេញលេញប្រកបដោយ ការទទួលខុសត្រូវខ្ពស់ ក្នុងការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា ដោយហេតុថា តួនាទី និងភារកិច្ចទាំងនោះមិនទាន់ត្រូវបានរៀបចំច្បាស់លាស់ ជាពិសេស រវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- កង្វះធនធាន (ធនធានមនុស្សដែលមានជំនាញផ្នែកសង្គមកិច្ច និងថវិកា) និងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីអនុវត្តការងារគ្រប់គ្រង និងដោះស្រាយបញ្ហាជនអនាថា។
- យន្តការកំណត់អត្តសញ្ញាណជនអនាថា មិនទាន់មានការចងក្រងទិន្នន័យគ្រប់ជ្រុងជ្រោយ និងមិនទាន់មានសុក្រឹតភាព ដែលអាចទាញយកមកប្រើប្រាស់ក្នុងការគ្រប់គ្រងជនអនាថា។
- ការគ្រប់គ្រង និងការផ្តល់សេវានៅតាមមណ្ឌលសំចត និងមជ្ឈមណ្ឌលឯកទេសសង្គមកិច្ចនានា ហាក់មិនទាន់មានប្រសិទ្ធភាព ដែលអាចឆ្លើយតបនឹងស្ថានភាពបច្ចុប្បន្ន។

## ១.២. ស្ថានភាពបញ្ហាជនអនាថា និងបទពិសោធថ្នាក់តំបន់

ប្រទេសនៅក្នុងតំបន់អាស៊ាន ជាអាទិ៍ ប្រទេសសិង្ហបុរី ហ្វីលីពីន និងឥណ្ឌូនេស៊ី បានកំណត់ និយមន័យនៃជនអនាថាមានលក្ខណៈស្រដៀងគ្នា ទៅតាមស្ថានភាពប្រជាសាស្ត្ររបស់ប្រទេសនីមួយៗ។ កត្តាចម្បងដែលបណ្តាលឱ្យមានបញ្ហាជនអនាថានៅតាមបណ្តាប្រទេសទាំងនោះ រួមមានវិសមភាព សេដ្ឋកិច្ច-សង្គម, ភាពក្រីក្រ, ភាពគ្មានការងារធ្វើ ឬមិនមានការងារជាប់លាប់, កង្វះសមត្ថភាពវិជ្ជាជីវៈ, ការធ្វើចំណាកស្រុកពីជនបទទៅទីក្រុងធំៗដើម្បីឱកាសរកចំណូល, បញ្ហាសុខភាព, បញ្ហាគ្រួសារ,

ការរើសអើងពីគ្រួសារសាច់ញាតិ ជាពិសេស ក្រុមអ្នកស្រលាញ់ភេទដូចគ្នា និងអ្នកប្តូរភេទ (LGBT), និងការជ្រើសរើសរស់នៅតាមទីសាធារណៈ ដោយស្ម័គ្រចិត្ត ដើម្បីសេរីភាពផ្ទាល់ខ្លួនជាដើម។

ជាការឆ្លើយតបនឹងបញ្ហាជនអនាថា, ប្រទេសសិង្ហបុរី និងឥណ្ឌូនេស៊ី បានដាក់ចេញនូវអន្តរាគមន៍កម្មវិធីផ្តល់ជំនួយមួយចំនួន រួមមានផ្តល់ទីជម្រកបណ្តោះអាសន្ន, ផ្តល់ការគាំទ្រនៅតាមមជ្ឈមណ្ឌលស្តារនីតិសម្បទា, ផ្តល់ការបណ្តុះបណ្តាលជំនាញ និងការងារ, ព្រមទាំងសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលដៃគូ ដើម្បីដោះស្រាយតម្រូវការចាំបាច់លើការផ្តល់ជាអាហារ និងគាំទ្រផ្នែកអនាម័យក្នុងការរស់នៅ ជាដើម។ រីឯប្រទេសហ្វីលីពីនឆ្លើយតបនឹងបញ្ហាជនអនាថាដោយផ្តោតការគិតគូរពីផ្នែកសុខុមាលភាពរបស់បុគ្គល និងការផ្តល់សេវាលំនៅឋាន។ ជនអនាថានៅប្រទេសហ្វីលីពីនរាប់បញ្ចូលទាំងអ្នករស់នៅតាមសំណង់អនាធិបតេយ្យ និងគ្រួសារដែលគ្មានទីជម្រកដោយរស់នៅតាមទីសាធារណៈ ប៉ុន្តែប្រទេសនេះមិនមានគោលនយោបាយដោយឡែក សម្រាប់ដោះស្រាយបញ្ហាជនអនាថានោះទេ ដោយគោលនយោបាយ និងអន្តរាគមន៍បច្ចុប្បន្ន នៅមានភាពបែកខ្ញែកគ្នាទៅតាមវិស័យសុខុមាលភាពបុគ្គល ដែលជាវិធានការគាំពារសង្គមបែបអន្តរកាល។

បន្ថែមពីនេះ, សម្រាប់ប្រទេសសិង្ហបុរី ក្រៅពីជនអនាថាដែលមិនមានផ្ទះសម្បែង ក៏មានជនអនាថាដែលមានផ្ទះសម្បែង តែជ្រើសរើសរស់នៅតាមទីសាធារណៈ។ ជាដំណោះស្រាយ, រដ្ឋាភិបាលសិង្ហបុរី បានលើកកម្ពស់សេវាផ្តល់ជម្រើសទីជម្រក ក៏ដូចជាផ្តល់ការប្រឹក្សាយោបល់ផ្នែកការងារ និងហិរញ្ញវត្ថុ ជាដើម។ នៅប្រទេសឥណ្ឌូនេស៊ី ជនអនាថា រួមមានក្រុមជនដើរសុំទាន, ជនគ្មានទីជម្រក, និងជនអនាថាមានពិការភាព ដែលពួកគេអាចជ្រើសយកការប្រើប្រាស់សេវាកម្មរបស់មជ្ឈមណ្ឌលស្តារនីតិសម្បទារបស់រដ្ឋបានរយៈពេល ៦ខែ ដើម្បីធ្វើសមាហរណកម្មទៅសហគមន៍វិញ ប៉ុន្តែពួកគេភាគច្រើនចាកចេញពីមជ្ឈមណ្ឌលមួយទៅស្នាក់នៅមជ្ឈមណ្ឌលមួយទៀត។

## ២. ចក្ខុវិស័យ

គោលនយោបាយស្តីពីការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា មានចក្ខុវិស័យ លើកកម្ពស់សុខុមាលភាព និងស្ថានភាពរស់នៅរបស់ជនអនាថាឱ្យប្រសើរឡើង ដើម្បីក្លាយជាកម្លាំងពលកម្មដែលរួមចំណែកក្នុងសកម្មភាពសង្គម-សេដ្ឋកិច្ច, ចូលរួមពង្រឹងសណ្តាប់ធ្នាប់សាធារណៈ សេចក្តីថ្លៃថ្នូរក្នុងសង្គម និងសោភ័ណភាពជាតិ, និងកាត់បន្ថយភាពអនាថាជាប្រព័ន្ធ ប្រកបដោយបរិយាបន្ន តាមរយៈការដោះស្រាយចំឫសគល់នៃបញ្ហា។

## ៣. គោលបំណង គោលដៅ និងគោលការណ៍

គោលនយោបាយស្តីពីការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា មានគោលបំណងផ្តល់នូវដំណោះស្រាយជាយុទ្ធសាស្ត្រ និងលក្ខណៈជាប្រព័ន្ធ, គ្រប់ជ្រុងជ្រោយ, ប្រកបដោយសង្គតិភាព ដើម្បីកាត់បន្ថយភាពអនាថា ដែលនឹងរួមចំណែកសម្រេចនូវគោលបំណងនៃគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ព្រមទាំងជំរុញការគាំទ្រលើសុខុមាលភាពជនអនាថា ដោយធានាលទ្ធភាពទទួលបានសេវាសង្គមកិច្ចសំខាន់ៗ និងអត្ថប្រយោជន៍នានាពីប្រព័ន្ធគាំពារសង្គម និងជំរុញការធ្វើសមាហរណកម្មជនអនាថាទៅក្នុងសហគមន៍វិញ។

ដើម្បីសម្រេចចក្ខុវិស័យ និងគោលបំណងខាងលើ, គោលនយោបាយស្តីពីការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា កំណត់គោលដៅចម្បងៗ ដូចខាងក្រោម៖

- បង្កើតយន្តការកំណត់អត្តសញ្ញាណជនអនាថា និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យជនអនាថា ដែលអាចភ្ជាប់ ជាមួយថ្នាល និងប្រព័ន្ធទិន្នន័យពាក់ព័ន្ធនានា,
- កែលម្អ និងពង្រឹងយន្តការបញ្ជូនបន្តជនអនាថាទៅទទួលសេវាចាំបាច់នានា,
- ពង្រឹងសេវាសង្គមកិច្ច ការស្តារនីតិសម្បទា និងការទទួលបានអត្ថប្រយោជន៍ពីកម្មវិធីជំនួយសង្គម និងរបបសន្តិសុខសង្គម ដើម្បីលើកកម្ពស់សុខុមាលភាពជនអនាថា,
- ពង្រឹង និងអភិវឌ្ឍយន្តការសមាហរណកម្មទៅក្នុងសហគមន៍វិញ និងទប់ស្កាត់ការវិលត្រលប់ទៅរកភាពអនាថា,
- រៀបចំប្រព័ន្ធអភិបាលកិច្ចច្បាស់លាស់ ដើម្បីពង្រឹងតួនាទី និងភារកិច្ចរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា ជាលក្ខណៈអន្តរវិស័យ អន្តរស្ថាប័ន និងជាប្រព័ន្ធ,
- ពង្រឹងភាពជាដៃគូ រវាងរាជរដ្ឋាភិបាល ជាមួយវិស័យឯកជន, ដៃគូអភិវឌ្ឍន៍, អង្គការសង្គមស៊ីវិល, និងភាគីពាក់ព័ន្ធផ្សេងៗ ក្នុងការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា,
- លើកកម្ពស់ការយល់ដឹងរបស់ពលរដ្ឋលើការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា។

ក្នុងការអនុវត្តការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា, គោលនយោបាយនេះកំណត់គោលការណ៍សំខាន់ៗ ដែលត្រូវប្រកាន់ខ្ជាប់ ដូចខាងក្រោម៖

- **សមភាព និងសមធម៌៖** ការគ្រប់គ្រង និងការផ្តល់កិច្ចគាំទ្រនានាដល់ជនអនាថា ត្រូវអនុវត្ត ប្រកបដោយស្មើភាព និងផ្តោតចម្បងលើភាពងាយរងគ្រោះ និងតម្រូវការជាក់ស្តែងរបស់បុគ្គល។
- **បរិយាបន្នសង្គម៖** ការអនុវត្តការគ្រប់គ្រង និងការផ្តល់កិច្ចគាំទ្រនានាដល់ជនអនាថា ត្រូវគិតគូរ ឱ្យបានទូលំទូលាយ និងគ្រប់ជ្រុងជ្រោយ ស្របតាមស្ថានភាពជាក់ស្តែងរបស់ក្រុមគោលដៅ ដោយផ្តោតលើផាសុកវត្ថុ, ផាសុកសមរម្យនៅគ្រប់មូលដ្ឋានផ្តល់សេវា និងអនុវត្តសកម្មភាព។
- **សិទ្ធិបុគ្គលជាមូលដ្ឋាន៖** ការងារពាក់ព័ន្ធនៅគ្រប់ដំណាក់កាល និងគ្រប់ទីកន្លែង ត្រូវអនុវត្ត ដោយគិតគូរដល់សិទ្ធិមនុស្សជាមូលដ្ឋាន រួមមាន ឯកជនភាព, ការរក្សាការសម្ងាត់, ការទទួល បានព័ត៌មានត្រឹមត្រូវ, ការសម្រេចចិត្ត និងការព្រមព្រៀង ជាដើម។
- **សេចក្តីថ្លៃថ្នូរ៖** ជនអនាថាត្រូវទទួលបានការគាំពារ គាំទ្រ និងគោរព ស្របតាមសេចក្តីថ្លៃថ្នូរ ក្នុងការរស់នៅ។
- **សុវត្ថិភាព៖** ការអនុវត្តការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា ត្រូវគិតគូរជាចម្បង អំពីសុវត្ថិភាពរបស់ជនអនាថា នៅគ្រប់ដំណាក់កាលទាំងអស់ ដោយធានាបាននូវការមិន ទទួលរងនូវការបៀតបៀន កេងប្រវ័ញ្ច ឬរំលោភបំពានគ្រប់រូបភាព។

# ៤. យុទ្ធសាស្ត្រ

ការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា ជាកិច្ចការមានលក្ខណៈអន្តរវិស័យ និងអន្តរស្ថាប័ន ដែលទាមទារឱ្យមានការផ្សារភ្ជាប់ រវាងគោលនយោបាយ, បទដ្ឋានគតិយុត្ត, ក្របខណ្ឌស្ថាប័ន និងអភិបាលកិច្ច, និងប្រតិបត្តិការក្នុងការផ្តល់សេវា ដើម្បីឈានទៅអនុវត្តការងារជាប្រព័ន្ធរួមមួយដែលមានភាពប្រទាក់ក្រឡា, មានប្រសិទ្ធភាព និងប្រកបដោយបរិយាបន្ន។ ក្នុងន័យនេះ និងដើម្បីសម្រេចបានចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ, គោលនយោបាយនេះដាក់ចេញយុទ្ធសាស្ត្រសំខាន់ៗ ដែលត្រូវអនុវត្តអនុលោមតាមគោលការណ៍ទាំង៥ ខាងលើ ដូចតទៅ៖

## ៤.១. អភិវឌ្ឍយន្តការកំណត់អត្តសញ្ញាណ និងគ្រប់គ្រងទិន្នន័យជនអនាថា

### ៤.១.១. ទិដ្ឋភាពទូទៅ និងបញ្ហាប្រឈម

កន្លងមក, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានធ្វើការកំណត់អត្តសញ្ញាណជនអនាថា ដោយប្រើប្រាស់វិធីសាស្ត្ររដ្ឋបាលដែលមិនមានការចុះបញ្ជីទិន្នន័យគ្រប់ជ្រុងជ្រោយ, ជាក់លាក់តាមប្រភេទ និងតាមស្ថានភាពរស់នៅរបស់ជនអនាថា ស្របតាមនីតិវិធីនៃការគ្រប់គ្រងករណីនៅឡើយ ដែលការណ៍នេះធ្វើឱ្យព័ត៌មាន និងទិន្នន័យជនអនាថា មិនទាន់មានសុក្រឹតភាព ដើម្បីអនុញ្ញាតឱ្យរាជរដ្ឋាភិបាលគ្រប់គ្រង និងផ្តល់អន្តរាគមន៍គាំទ្រជនអនាថាបានពេញលេញ និងប្រកបដោយចីរភាពបានឡើយ។ ជនអនាថាភាគច្រើនចល័ត ពីមួយកន្លែង ទៅមួយកន្លែងក្នុងទីប្រជុំជន និងតំបន់ទេសចរណ៍ ហើយជនអនាថាមួយចំនួនបានយកការដើរសុំទានជាអាជីព ដោយជួលផ្ទះ ឬស្នាក់នៅជាមួយបងប្អូនដើម្បីចេញប្រកបការងារនេះ។ មុខសញ្ញាជនអនាថាខ្លះទៀត មានផ្ទះនៅទីជនបទ និងបានទទួលបណ្ណសមធម៌ និងប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាលផងដែរ ប៉ុន្តែជ្រើសរើសការសុំទានតាមទីសាធារណៈជាមុខរបរបន្ថែម។ ភាពស្មុគស្មាញនេះ បានបង្កការលំបាកដល់ការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។ ផ្អែកលើកត្តានេះ, ការអភិវឌ្ឍយន្តការកំណត់អត្តសញ្ញាណ និងគ្រប់គ្រងទិន្នន័យជនអនាថា ដែលមានសុក្រឹតភាព, គ្រប់ជ្រុងជ្រោយ, ជាក់លាក់ទៅតាមប្រភេទ និងស្ថានភាពរស់នៅរបស់ជនអនាថា មានភាពចាំបាច់ក្នុងការដោះស្រាយ និងគ្រប់គ្រងជនអនាថា ប្រកបដោយប្រសិទ្ធភាព និងបរិយាបន្ន។

### ៤.១.២. វិធានការចម្បង

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ, រាជរដ្ឋាភិបាលដាក់ចេញវិធានការចម្បងៗមួយចំនួនដូចខាងក្រោម៖

- រដ្ឋបាលរាជធានី-ខេត្ត ត្រូវពង្រឹងយន្តការប្រមូលផ្តុំជនអនាថាទៅកន្លែងសំចតសុវត្ថិភាព ដោយសហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងភាគីពាក់ព័ន្ធ ដើម្បីកំណត់អត្តសញ្ញាណបឋម ដូចជាប្រភេទ, ប្រវត្តិរូប, និងស្ថានភាពរស់នៅរបស់ជនអនាថា ដើម្បីបញ្ជូនបន្តទៅរកកន្លែងផ្តល់សេវាផ្សេងៗ។ ក្នុងករណីរកឃើញថា ជនអនាថាណាមួយរង

ការកេងប្រវ័ញ្ច ឬការជួញដូរកម្លាំងពលកម្មដោយមេខ្យល់, កន្លែងសំចតសុវត្ថិភាពត្រូវរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច និងសហការស្រាវជ្រាវកំណត់មុខសញ្ញាបណ្តាញមេខ្យល់។

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រៀបចំបង្កើតនីតិវិធីប្រតិបត្តិសម្រាប់កំណត់អត្តសញ្ញាណជនអនាថា ដោយកំណត់ប្រភេទ, ប្រវត្តិរូប, និងស្ថានភាពរស់នៅរបស់ជនអនាថា ឱ្យបានច្បាស់លាស់ ដើម្បីបញ្ជូនបន្តទៅកន្លែងផ្តល់សេវាផ្សេងៗ ឬធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ ប្រកបដោយប្រសិទ្ធភាព។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវគ្រប់គ្រងទិន្នន័យនៃប្រភេទ ប្រវត្តិរូប និងស្ថានភាពរស់នៅរបស់ជនអនាថា ដោយត្រូវរៀបចំបង្កើតប្រព័ន្ធចុះបញ្ជី និងប្រព័ន្ធឌីជីថលគ្រប់គ្រងទិន្នន័យជនអនាថា ដោយពិនិត្យលទ្ធភាព ក្នុងការពង្រីកវិសាលភាពប្រព័ន្ធទិន្នន័យដែលមានស្រាប់ ( Integrated Social Services Case Management System - ICMS ) និងលទ្ធភាពផ្សារភ្ជាប់ជាមួយប្រព័ន្ធទិន្នន័យចុះបញ្ជីគាំពារសង្គម និងប្រព័ន្ធទិន្នន័យផ្សេងៗ ដើម្បីជំរុញការទទួលបានអត្ថប្រយោជន៍គាំពារសង្គមដល់ជនអនាថា។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវពង្រឹងការអង្កេតរហ័សដោយអនុវត្តជាទៀងទាត់ និងចងក្រងទិន្នន័យ ដើម្បីជាជំនួយដល់យន្តការកំណត់អត្តសញ្ញាណខាងលើ និងសម្រាប់បម្រើជាប្រយោជន៍ដល់ការរៀបចំរបាយការណ៍ និងឯកសារគតិយុត្តផ្សេងៗតាមការចាំបាច់។

## ៤.២. ពង្រឹងអភិបាលកិច្ច ភាពជាដៃគូ និងយន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូ

### ៤.២.១. ទិដ្ឋភាពទូទៅ និងបញ្ហាប្រឈម

ការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា ត្រូវបានទទួលស្គាល់ថា ជាកិច្ចការមានលក្ខណៈអន្តរវិស័យ និងអន្តរស្ថាប័ន ដែលទាមទារឱ្យមានការបែងចែកតួនាទី និងភារកិច្ចក្រសួង-ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានច្បាស់លាស់ ក៏ដូចជាការចូលរួមយ៉ាងសកម្ម និងមានទំនួលខុសត្រូវខ្ពស់ពីក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ និងគ្រប់ភាគីពាក់ព័ន្ធ។ ផ្អែកលើលក្ខណៈអន្តរវិស័យ និងអន្តរស្ថាប័ននៃការដោះស្រាយបញ្ហាជនអនាថា, ការពង្រឹងអភិបាលកិច្ច ភាពជាដៃគូ និងយន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូ ជាចលករចាំបាច់ក្នុងការជំរុញអនុវត្តការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា ឱ្យកាន់តែមានប្រសិទ្ធភាព និងនិរន្តរភាព។

### ៤.២.២. វិធានការចម្បង

ដើម្បីដោះស្រាយបញ្ហាប្រឈមខាងលើ, រាជរដ្ឋាភិបាលដាក់ចេញវិធានការចម្បងៗមួយចំនួនដូចខាងក្រោម៖

- ត្រូវបានរៀបចំប្រព័ន្ធអភិបាលកិច្ចក្នុងការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា ដោយបែងចែកជា ២កម្រិត ជាក់លាក់ ដូចខាងក្រោម៖

- **កម្រិតគោលនយោបាយ៖** មានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាស្ថាប័នដឹកនាំសម្របសម្រួលគ្រប់គ្រង និងដោះស្រាយបញ្ហាជនអនាថា នៅកម្រិតគោលនយោបាយ ជាមួយក្រសួង-ស្ថាប័នថ្នាក់ជាតិពាក់ព័ន្ធ តាមរយៈគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា (គ.ជ.អ) និងអនុគណៈកម្មាធិការដោះស្រាយបញ្ហាជនអនាថា រាជធានី-ខេត្ត (អ.គ.អ) ដែល គ.ជ.អ និង អ.គ.អ អាចត្រូវបានកែសម្រួលតាមភាពចាំបាច់។
- **កម្រិតប្រតិបត្តិ៖** មានរដ្ឋបាលរាជធានី-ខេត្តនៅទូទាំងប្រទេស ទទួលបន្ទុកគ្រប់គ្រងកន្លែងសំចតសុវត្ថិភាព និងគ្រប់គ្រងការប្រមូលផ្តុំជនអនាថានៅតាមមូលដ្ឋាន។ រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវដឹកនាំគាំទ្រ និងសហការជាមួយមន្ទីរសង្គមកិច្ច អតីត-យុទ្ធជន និងយុវនីតិសម្បទា ដើម្បីធ្វើការកំណត់អត្តសញ្ញាណបឋម មុននឹងបញ្ជូនបន្តទៅទទួលសេវាចាំបាច់នៅតាមមជ្ឈមណ្ឌលឯកទេសសង្គមកិច្ចផ្សេងៗ។

- លើកកម្ពស់ភាពជាដៃគូរវាងរាជរដ្ឋាភិបាល វិស័យឯកជន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធ ក្នុងការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា។
- បង្កើតយន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ ដែលអាចជាទម្រង់សន្និសីទករណី (case conference) ឬទម្រង់ប្រហាក់ប្រហែល សម្រាប់ការងារដោះស្រាយបញ្ហាជនអនាថា។
- ជំរុញការប្រាស្រ័យទាក់ទងគ្នា ចែករំលែក និងផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវលើបទពិសោធ ចំណេះដឹង នវានុវត្តន៍ ព័ត៌មាន និងទិន្នន័យលើគ្រប់ទិដ្ឋភាព រវាងភាគីពាក់ព័ន្ធក្នុងការងារគ្រប់គ្រង និងដោះស្រាយបញ្ហាជនអនាថា ដោយរៀបចំឱ្យមាននីតិវិធី (ពិធីសារ) សម្រាប់ការងារនេះ។

## ៤.៣. រៀបចំកន្លែងសំចតសុវត្ថិភាព និងមជ្ឈមណ្ឌលឯកទេសសង្គមកិច្ច

### ៤.៣.១. ទិដ្ឋភាពទូទៅ និងបញ្ហាប្រឈម

កន្លងមក, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានបង្កើតមណ្ឌលសំចត ដូចជា៖ មជ្ឈមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ (ព្រៃស្ពឺ), មជ្ឈមណ្ឌលសំចតសង្គមកិច្ច ខេត្តសៀមរាប, និងមជ្ឈមណ្ឌលសំចតសង្គមកិច្ច ខេត្តបាត់ដំបង។ បន្ថែមលើមណ្ឌលសំចតទាំងនេះ, មជ្ឈមណ្ឌលឯកទេសសង្គមកិច្ចមួយចំនួនត្រូវបានបង្កើតឡើងផងដែរដើម្បីផ្តល់សេវាសង្គមកិច្ចដល់ជនរងគ្រោះ និងងាយរងគ្រោះ ដែលរួមមានទាំងជនអនាថាផងដែរ។ មជ្ឈមណ្ឌលឯកទេសសង្គមកិច្ច ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រួមមានប្រភេទដូចជា៖

- មជ្ឈមណ្ឌលផ្តល់សេវាថែទាំ និងស្តារនីតិសម្បទាជនវិបល្លាសស្មារតី
- មជ្ឈមណ្ឌលផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស
- មជ្ឈមណ្ឌលផ្តល់សេវាថែទាំជំនួសចំពោះកុមារ

- មជ្ឈមណ្ឌលផ្តល់សេវាស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន
- មជ្ឈមណ្ឌលផ្តល់សេវាស្តារនីតិសម្បទាអនីតិជនទំនាស់នឹងច្បាប់
- មជ្ឈមណ្ឌលផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជូនជនមានពិការភាព
- មជ្ឈមណ្ឌលផ្តល់សេវាស្តារលទ្ធភាពពលកម្មវេជ្ជសាស្ត្រអ្នកជំងឺរបួសខួរឆ្អឹងខ្នង។

ផ្អែកតាមស្ថានភាពបច្ចុប្បន្ន, ការគ្រប់គ្រងមជ្ឈមណ្ឌលខាងលើនៅមិនទាន់មានភាពច្បាស់លាស់ និងមិនមានក្របខណ្ឌរួមនៃការបែងចែកការទទួលខុសត្រូវគ្រប់គ្រងមជ្ឈមណ្ឌល ឱ្យបានជាក់លាក់នៅឡើយ ដោយមានមជ្ឈមណ្ឌលខ្លះគ្រប់គ្រងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងខ្លះទៀតគ្រប់គ្រងដោយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងរដ្ឋបាលរាជធានី-ខេត្តផ្ទាល់។ ជាក់ស្តែង, ការរៀបចំបង្កើតមណ្ឌលមួយចំនួន មិនទាន់អនុលោមតាមនីតិវិធី និងបទដ្ឋានគតិយុត្តជាធរមាននៅឡើយ ក្នុងចំណោមមណ្ឌលសំចតនីមួយៗ។ ការណ៍នេះ បង្កើតភាពស្មុគស្មាញក្នុងការគ្រោង និងអនុវត្តថវិការដ្ឋសម្រាប់គាំទ្រប្រតិបត្តិការ ហើយការស្នើសុំបង្កើតមណ្ឌលសំចត និងមជ្ឈមណ្ឌលឯកទេសសង្គមកិច្ចថ្មីក្នុងចំនួនច្រើន ដាច់ដោយឡែកពីគ្នា នាំមកនូវបន្ទុកថវិកា និងការអនុវត្តមិនមានប្រសិទ្ធភាព។ ទន្ទឹមនេះ, មជ្ឈមណ្ឌលដែលមានបច្ចុប្បន្ន ហាក់ពុំទាន់មានភាពគ្រប់គ្រាន់ សម្រាប់ការដោះស្រាយបញ្ហាជនអនាថាឱ្យមានប្រសិទ្ធភាព និងសម្រេចបានជោគជ័យ ទោះបីជាមិនទាន់មានការសិក្សា និងវិភាគឱ្យបានស៊ីជម្រៅអំពីតម្រូវការជាក់ស្តែងនៅឡើយ។

### ៤.៣.២. វិធានការចម្បង

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ រាជរដ្ឋាភិបាលកំណត់នូវវិធានការចម្បង ដូចខាងក្រោម៖

- រដ្ឋបាលរាជធានី-ខេត្តត្រូវរៀបចំកន្លែងសំចតសុវត្ថិភាព សម្រាប់ផ្តល់ការស្នាក់នៅបណ្តោះអាសន្ន និងកំណត់អត្តសញ្ញាណបឋម (ក្នុងរយៈពេលយ៉ាងយូរ ៧២ម៉ោង និងត្រូវកំណត់ដោយនីតិវិធីប្រតិបត្តិ) សម្រាប់ជនអនាថា មុននឹងបញ្ជូនបន្តទៅទទួលសេវាចាំបាច់នៅតាមមជ្ឈមណ្ឌលឯកទេសសង្គមកិច្ចផ្សេងៗទៅតាមស្ថានភាពជាក់ស្តែងរបស់បុគ្គល ឬសមាហរណកម្មទៅមូលដ្ឋានរៀងៗខ្លួន បន្ទាប់ពីទទួលបានការអប់រំ និងបណ្តុះបណ្តាលបំណិនជីវិត។ ក្នុងករណីមានតម្រូវការកន្លែងសំចតសុវត្ថិភាពបន្ថែម, រដ្ឋបាលរាជធានី-ខេត្តនីមួយៗ ត្រូវសិក្សាពីតម្រូវការ ដើម្បីជាអំណះអំណាង សម្រាប់ការស្នើសុំរៀបចំឱ្យមានកន្លែងសំចតសុវត្ថិភាពដោយប្រើប្រាស់ធនធានផ្ទាល់របស់រាជធានី-ខេត្ត តាមការចាំបាច់។
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវសិក្សាលទ្ធភាពរៀបចំកែសម្រួលមណ្ឌលសំចតដែលមានស្រាប់ឱ្យទៅជា មជ្ឈមណ្ឌលថែទាំ និងស្តារនីតិសម្បទាជនរងគ្រោះ ឬមជ្ឈមណ្ឌលឯកទេសសង្គមកិច្ចផ្សេងៗ លើកលែងមណ្ឌលសំចតសម្រាប់ទទួលជនរងគ្រោះដោយករណីជួញដូរមនុស្ស។ ក្នុងករណីមានបញ្ហាប្រឈមកង្វះខាតមជ្ឈមណ្ឌល, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវសិក្សាឱ្យបានច្បាស់លាស់លើតម្រូវការជាក់ស្តែង និងភាពចាំបាច់ ដើម្បីជាអំណះអំណាង សម្រាប់ការស្នើសុំរៀបចំមជ្ឈមណ្ឌលឯកទេសសង្គមកិច្ចបន្ថែម។

- ក្រសួងធម្មការ និងសាសនា ដោយសហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចសិក្សាលទ្ធភាពប្រើប្រាស់ធនធានដែលមានស្រាប់នៅវត្តអារាមព្រះពុទ្ធសាសនា ឬវិហារពាហិរសាសនា ដើម្បីផ្តល់ការស្នាក់នៅ ការសំចត និងការគាំទ្រនានា ជាពិសេសការអប់រំផ្លូវចិត្តតាមគន្លងសាសនា តាមការចាំបាច់ ដល់ជនអនាថា ជាមនុស្សចាស់គ្មានទីពឹងផ្អែកតាមស្ថានភាពជាក់ស្តែង និងតម្រូវការរបស់ពួកគាត់ ព្រមទាំងសិក្សារៀបចំក្រមប្រតិបត្តិផ្ទៃក្នុងសម្រាប់អនុវត្តកិច្ចការគាំទ្រនេះ។
- អភិវឌ្ឍ និងពង្រឹងយន្តការអភិបាលកិច្ចរបស់កន្លែងសំចតសុវត្ថិភាព និងមជ្ឈមណ្ឌលឯកទេសសង្គមកិច្ចនានា។
- បង្កើតក្រមប្រតិបត្តិរួមសម្រាប់គ្រប់គ្រង និងអនុវត្តការងារក្នុងកន្លែងសំចតសុវត្ថិភាព និងមជ្ឈមណ្ឌលឯកទេសសង្គមកិច្ចនានា ដែលបម្រើដល់ការងារដោះស្រាយបញ្ហាជនអនាថាឱ្យមានស្តង់ដារួមនៅទូទាំងប្រទេស។
- គណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា ត្រូវរៀបចំបង្កើតយន្តការតាមដាន វាយតម្លៃ និងទទួលមតិយោបល់លើការអនុវត្តការគ្រប់គ្រង និងអនុវត្តការងារក្នុងកន្លែងសំចតសុវត្ថិភាព ដែលមានរដ្ឋបាលរាជធានី-ខេត្តជាប្រតិបត្តិករទទួលបន្ទុក ដើម្បីជាមូលដ្ឋានក្នុងការសិក្សាតម្រូវការ និងការពង្រឹង និងកែសម្រួលយន្តការគ្រប់គ្រងជាបន្តបន្ទាប់។

## ៤.៤. អភិវឌ្ឍយន្តការចាំបាច់សម្រាប់ការទទួលបានសេវាបំពេញបន្ថែម និងអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គម

### ៤.៤.១. អភិវឌ្ឍយន្តការចាំបាច់សម្រាប់ការបញ្ជូនបន្តទៅទទួលបានសេវាបំពេញបន្ថែម

#### ៤.៤.១.១. ទិដ្ឋភាពទូទៅ និងបញ្ហាប្រឈម

ក្នុងដំណើរការគាំទ្រ និងដោះស្រាយបញ្ហាជនអនាថា, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បាន និងកំពុងផ្តល់សេវាសង្គមកិច្ចសំខាន់ៗ រួមមានសេវាដោះស្រាយបញ្ហាទប់ស្កាត់ និងការពារជនអនាថា, សេវានីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់សារធាតុញៀន, សេវាថែទាំជំនួសចំពោះកុមារ, សេវាទទួលថែទាំ និងព្យាបាលជនវិបល្លាសស្មារតី, សេវាស្តារលទ្ធភាពពលកម្មកាយសម្បទាជូនជនមានពិការភាព, សេវាស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ, សេវាបណ្តុះបណ្តាលវិជ្ជាជីវៈជូនជនមានពិការភាព, សេវាស្តារនីតិសម្បទាអនីតិជនទំនាស់នឹងច្បាប់ និងសេវាផ្សេងៗទៀត។

បច្ចុប្បន្ន, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បាន និងកំពុងអនុវត្តការងារផ្តល់សេវាគ្រប់គ្រងករណីដោយប្រើប្រាស់មន្ត្រីសង្គមកិច្ចដែលមានស្រាប់ និងការរៀបចំប្រមូលផ្តុំកម្លាំងសេវាសង្គមពីដៃគូពាក់ព័ន្ធ ដោយប្រើប្រាស់ជំនាញប៉ាន់ប្រមាណ, ការប្រាស្រ័យទាក់ទង, និងវាយតម្លៃទៅលើជនរងគ្រោះ និងងាយរងគ្រោះ ដើម្បីកំណត់ហានិភ័យ និងរៀបចំផែនការជួយដោះស្រាយ

បញ្ហាជនរងគ្រោះ ឬគ្រួសាររបស់ពួកគេក្នុងរបៀបសមស្របអនុលោមតាមគោលការណ៍នីតិវិធីដែលមានស្រាប់ និងតាមរយៈការគាំទ្រដោយផ្ទាល់ ឬបញ្ជូនបន្តទៅសេវាសង្គមផ្សេងៗ។ យ៉ាងណាមិញ, យន្តការនៃការបញ្ជូនបន្តនេះ នៅមិនទាន់មានប្រសិទ្ធភាព និងគ្រប់ជ្រុងជ្រោយនៅឡើយ ដោយសារកត្តាប្រឈមមួយចំនួន ដូចជាកង្វះកម្លាំងសេវាសង្គមដែលមានវិជ្ជាជីវៈតាមប្រភេទសេវានីមួយៗ, ចំណេះជំនាញ និងគុណភាពសេវានៅមានកម្រិត, កង្វះធនធានសម្រាប់ការផ្តល់សេវា, កិច្ចសហការជាមួយភាគីពាក់ព័ន្ធនៅមានកម្រិត, និងមិនមានយន្តការរួមមួយសម្រាប់ការបញ្ជូនបន្តនៅឡើយ។

#### ៤.៤.១.២. វិធានការចម្បង

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ, រាជរដ្ឋាភិបាលដាក់ចេញវិធានការចម្បងៗ ដូចជាៈ

- រៀបចំបង្កើតយន្តការរួមសម្រាប់ការបញ្ជូនបន្តពីកន្លែងសំចតសុវត្ថិភាពទៅកាន់សេវាសង្គមកិច្ចនៅតាមមជ្ឈមណ្ឌលឯកទេសសង្គមកិច្ចផ្សេងៗ, អត្ថប្រយោជន៍គាំពារសង្គម, និងសេវាគាំទ្រនានា ដោយមានគោលការណ៍ណែនាំអំពីប្រព័ន្ធបញ្ជូន-ទទួល និងដោយតភ្ជាប់ជាមួយយន្តការកំណត់អត្តសញ្ញាណជនអនាថា។
- ធ្វើបច្ចុប្បន្នភាពសៀវភៅកម្រងព័ត៌មានអំពីសេវាសង្គមកិច្ច, ចងក្រងបញ្ជីអត្ថប្រយោជន៍គាំពារសង្គម និងសេវាគាំទ្រនានាដែលមានស្រាប់ ដើម្បីប្រើប្រាស់ជាមគ្គុទេសក៍សម្រាប់ជួយសម្រួលដល់យន្តការបញ្ជូនបន្ត។
- ពង្រឹងគុណភាព និងប្រសិទ្ធភាពសេវាសង្គមកិច្ចដែលមានស្រាប់ ដោយផ្តោតលើសេវាបង្ការនិងទប់ស្កាត់ការធ្លាក់ចូលក្នុងភាពអនាថា។
- ពង្រឹងសមត្ថភាព និងគុណភាពការផ្តល់សេវារបស់កម្លាំងសេវាសង្គម តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលជាទៀងទាត់ដើម្បីបំប៉នជំនាញផ្សេងៗ លើការងារគ្រប់គ្រងករណី, ការបញ្ជូនបន្តទៅរកសេវា, និងការធ្វើសមាហរណកម្មទៅគ្រួសារ ឬសហគមន៍វិញ។
- ពង្រឹងប្រព័ន្ធគ្រប់គ្រងករណីសេវាសង្គមកិច្ច និងធ្វើការតភ្ជាប់ប្រព័ន្ធគ្រប់គ្រងទិន្នន័យជាមួយក្រសួង-ស្ថាប័នដែលផ្តល់សេវា និងអត្ថប្រយោជន៍ពាក់ព័ន្ធ។
- រៀបចំនីតិវិធីប្រតិបត្តិនៃកិច្ចសម្របសម្រួលការបញ្ជូនបន្តរវាងអន្តរស្ថាប័ន។

### ៤.៤.២. លើកកម្ពស់ការទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គម

#### ៤.៤.២.១. ទិដ្ឋភាពទូទៅ និងបញ្ហាប្រឈម

ជាផ្នែកមួយនៃការឆ្លើយតបនឹងបញ្ហាជនអនាថា, ការលើកកម្ពស់សុខុមាលភាព និងជីវភាពសមរម្យរបស់ជនអនាថា ជាមូលដ្ឋានគ្រឹះដើម្បីជំរុញការធ្វើសមាហរណកម្មទៅគ្រួសារ ឬសហគមន៍វិញប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។ បច្ចុប្បន្ន, រាជរដ្ឋាភិបាលបាន និងកំពុងផ្តល់អត្ថប្រយោជន៍នានាពីប្រព័ន្ធគាំពារសង្គមដល់ពលរដ្ឋគ្រប់រូប ជាពិសេសគ្រួសារក្រីក្រ គ្រួសារងាយរងហានិភ័យ និងជនងាយរងគ្រោះ ដោយក្នុងនោះ ជនអនាថាមួយចំនួនក៏កំពុងទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមតាមរយៈយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងបានទទួលបណ្ណសមធម៌ ឬបណ្ណ

សម្គាល់គ្រួសារងាយរងហានិភ័យ ផងដែរ។ ដោយឡែក, ជនអនាថាមួយចំនួនទៀតបម្លាស់ទីលំនៅពីមួយកន្លែង ទៅមួយកន្លែងជាញឹកញាប់ និងពុំមានឯកសារបញ្ជាក់ទីលំនៅពិតប្រាកដ ឬឯកសារបញ្ជាក់អត្តសញ្ញាណ ដែលជាឯកសារចម្បងសម្រាប់ទទួលបានការវាយតម្លៃពីយន្តការអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ដើម្បីទទួលបានអត្ថប្រយោជន៍គាំពារសង្គមនានា។ ទន្ទឹមនេះ, ការផ្តល់នូវការគាំពារ និងការថែទាំសុខភាព តាមរយៈប្រព័ន្ធគាំពារសង្គម នឹងជួយបំពេញបន្ថែមលើអន្តរាគមន៍ដោះស្រាយបញ្ហាជនអនាថា ឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

៤.៤.២.២. វិធានការចម្បង

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ, រាជរដ្ឋាភិបាលដាក់ចេញវិធានការចម្បងៗ ដូចជា៖

- ធ្វើការតភ្ជាប់ប្រព័ន្ធទិន្នន័យជនអនាថាដែលនឹងត្រូវបានចុះបញ្ជី ជាមួយនឹងប្រព័ន្ធទិន្នន័យចុះបញ្ជីគាំពារសង្គម ដើម្បីកំណត់ស្ថានភាពក្រីក្ររបស់ជនអនាថាសម្រាប់ផ្តល់អត្ថប្រយោជន៍ ពីប្រព័ន្ធគាំពារសង្គមតាមលក្ខខណ្ឌរបស់ពួកគេ
- ក្នុងករណីបុគ្គល ឬគ្រួសារជាជនអនាថាមិនមានព័ត៌មានក្នុងមូលដ្ឋានទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ក្រសួងផែនការ, ត្រូវជំរុញធ្វើការកំណត់អត្តសញ្ញាណពួកគេ ដើម្បីផ្តល់បណ្ណសមធម៌ ឬបណ្ណសម្គាល់គ្រួសារងាយរងហានិភ័យទៅតាមស្ថានភាពជាក់ស្តែងរបស់ជនអនាថា និងផ្តល់អត្ថប្រយោជន៍ ពីប្រព័ន្ធគាំពារសង្គម ផ្អែកលើលក្ខណៈវិនិច្ឆ័យនៃកម្មវិធីនីមួយៗ។
- ក្នុងករណីជនអនាថាមិនមានឯកសារគ្រប់គ្រាន់សម្រាប់ការធ្វើអត្តសញ្ញាណកម្មគ្រួសារក្រីក្រ, រដ្ឋបាលរាជធានី-ខេត្តត្រូវសម្របសម្រួលពាក់ព័ន្ធនឹងការផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ ដូចជាអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬឯកសារបញ្ជាក់ទីលំនៅអចិន្ត្រៃយ៍ ជាអាទិ៍ ទៅតាមលទ្ធភាព និងស្ថានភាពជាក់ស្តែង ដើម្បីជំរុញការចុះបញ្ជីជនអនាថាទៅក្នុងប្រព័ន្ធគាំពារសង្គម។
- ក្រសួងផែនការ ត្រូវសិក្សាលទ្ធភាពពង្រីកវិសាលភាពយន្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រដល់ជនអនាថាដែលចូលមកនៅមជ្ឈមណ្ឌលឯកទេសសង្គមកិច្ចនានា ដើម្បីលើកកម្ពស់ការទទួលបានអត្ថប្រយោជន៍គាំពារសង្គមផ្សេងៗ។
- ក្រសួងសុខាភិបាល និងក្រសួង-ស្ថាប័នពាក់ព័ន្ធ សិក្សាលទ្ធភាពផ្តល់សេវាសុខាភិបាលជូនជនអនាថា ដោយរដ្ឋបង់ថ្លៃជំនួស នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ដែលនៅក្បែរកន្លែងកើតហេតុ ឬនៅក្បែរកន្លែងសំចតសុវត្ថិភាព ឬនៅក្បែរមជ្ឈមណ្ឌលឯកទេសសង្គមកិច្ច ចំពោះជនអនាថាដែលកំពុងស្នាក់នៅបណ្តោះអាសន្ន ក្នុងកន្លែងសំចតសុវត្ថិភាព និងមជ្ឈមណ្ឌលឯកទេសសង្គមកិច្ច។ ក្នុងករណីជនអនាថាមិនទាន់ត្រូវបានកំណត់អត្តសញ្ញាណ, មូលដ្ឋានសុខាភិបាលសាធារណៈ ត្រូវផ្តល់សេវាសុខាភិបាល ហើយត្រូវជូនដំណឹងដល់កន្លែងសំចតសុវត្ថិភាពដើម្បីកំណត់អត្តសញ្ញាណជនអនាថា។

## ៤.៥. អភិវឌ្ឍយន្តការសមាហរណកម្មជនអនាថាទៅក្នុងសហគមន៍វិញ

### ៤.៥.១. ទិដ្ឋភាពទូទៅ និងបញ្ហាប្រឈម

សមាហរណកម្មទៅក្នុងសហគមន៍ ជាដំណាក់កាលនៃការបញ្ជូនជនអនាថាឱ្យទៅរួមរស់ជួបជុំជាមួយគ្រួសារសាច់ញាតិ នៅក្នុងសហគមន៍វិញ។ បច្ចុប្បន្ន អន្តរាគមន៍នេះនៅមិនទាន់មានប្រសិទ្ធភាព ដោយសារយន្តការគ្រប់គ្រង, ការសម្របសម្រួល, និងការតាមដានត្រួតពិនិត្យ មិនទាន់មានលក្ខណៈជាប្រព័ន្ធ និងមិនទាន់អនុវត្តត្រឹមត្រូវតាមនីតិវិធីនៃការគ្រប់គ្រងករណី ដែលការណ៍នេះធ្វើឱ្យជនអនាថាវិលត្រលប់មកនៅតាមដងផ្លូវ និងតាមទីសាធារណៈវិញ។ ដើម្បីផ្តល់ដំណោះស្រាយលើបញ្ហានេះ, ការបង្កើតយន្តការសមាហរណកម្មទៅក្នុងសហគមន៍វិញមានភាពចាំបាច់ ដោយយន្តការនេះត្រូវរួមបញ្ចូលទាំងការផ្តល់ការអប់រំ និងបណ្តុះបណ្តាលជំនាញ និងបំណិនជីវិត ក៏ដូចជាសេវាសង្គមកិច្ច និងសេវាគាំទ្រនានាដែលបុគ្គលត្រូវការ មុននឹងធ្វើសមាហរណកម្មទៅសហគមន៍វិញ ដើម្បីធានាប្រសិទ្ធភាព និងនិរន្តរភាព។

#### ៤.៥.២. វិធានការចម្បង

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ, រាជរដ្ឋាភិបាលដាក់ចេញវិធានការចម្បងៗ ដូចជា៖

- កែលម្អនីតិវិធី និងយន្តការនៃការធ្វើសមាហរណកម្មជនអនាថាទៅក្នុងសហគមន៍វិញ ព្រមទាំងពង្រឹងការអនុវត្ត។
- រៀបចំក្រុមការងារសមាហរណកម្មជនអនាថាទៅក្នុងសហគមន៍វិញដែលមានតួនាទី និងភារកិច្ចច្បាស់លាស់ ដោយប្រើប្រាស់សមាសភាពមន្ត្រីអនុវត្ត ឬក្រុមការងារដែលមានស្រាប់។
- រៀបចំផែនការសមាហរណកម្មជនអនាថាទៅក្នុងសហគមន៍វិញ ដោយគិតគូរផ្តល់ការបណ្តុះ-បណ្តាល អប់រំពង្រឹងសមត្ថភាព, ការផ្តល់ឱកាសការងារ, ការផ្តល់លំនៅឋានសមរម្យតាមរយៈគោលនយោបាយសម្បទានដីសង្គមកិច្ច, និងការផ្តល់ជំនួយហិរញ្ញវត្ថុ ឬកម្ចីខ្នាតតូចសម្រាប់ការកសាងអាជីវកម្ម។
- កត់ត្រា ចងក្រងទិន្នន័យ ឬបង្កើតប្រព័ន្ធតាមដានឌីជីថល ដោយកំណត់សូចនាករច្បាស់លាស់អំពីចំនួនជនអនាថាដែលត្រូវបានធ្វើសមាហរណកម្មទៅសហគមន៍វិញ ព្រមទាំងទីតាំងការងារដែលមានសុវត្ថិភាព និងអត្រានៃការស្តារឡើងវិញជាដើម។
- បង្កើនកិច្ចសហការរវាងស្ថាប័នរដ្ឋ អង្គការដៃគូពាក់ព័ន្ធ វិស័យឯកជន និងសហគមន៍ក្នុងមូលដ្ឋាន ដើម្បីកៀរគរការបណ្តុះបណ្តាលជំនាញ និងបំណិនជីវិត និងឱកាសការងារ ព្រមទាំងដំណោះស្រាយលំនៅឋានតម្លៃសមរម្យ។
- ពង្រឹងអភិបាលកិច្ច និងយន្តការសម្របសម្រួល ដើម្បីជំរុញការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការធ្វើសមាហរណកម្មជនអនាថាទៅសហគមន៍វិញ។

### ៤.៦. លើកកម្ពស់ការយល់ដឹងដល់សហគមន៍

#### ៤.៦.១. ទិដ្ឋភាពទូទៅ និងបញ្ហាប្រឈម

ការចូលរួមរបស់សហគមន៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាជនអនាថា និងការលើកកម្ពស់សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងសង្គម។ កន្លងមក ប្រជាជនតាមមូលដ្ឋាន

បានចូលរួមយ៉ាងល្អក្នុងការដោះស្រាយបញ្ហាជនអនាថា តាមរយៈការជូនដំណឹងដល់សមត្ថកិច្ចអំពីទីកន្លែងជនអនាថាធ្វើសកម្មភាពសុំទាន ឬជនវិបល្លាសស្មារតីដើរតែលតោលតាមផ្លូវ និងទីសាធារណៈ ក្នុងគោលបំណងប្រមូលផ្តុំយកទៅធ្វើការអប់រំ និងផ្តល់សេវាសង្គមកិច្ចចាំបាច់នានាជូនដល់ពួកគេ។ បច្ចុប្បន្ន, ប្រជាជនមួយចំនួនធំតែងគិតថាការឱ្យទានដល់ជនអនាថា ជាទង្វើបង្ហាញអំពីទឹកចិត្តសប្បុរសធម៌ និងចែករំលែកជួយគ្នាក្នុងគ្រាលំបាក ប៉ុន្តែការឱ្យទានដល់ជនអនាថាមិនអាចផ្លាស់ប្តូរជីវិតរបស់ពួកគេបានទេ ផ្ទុយទៅវិញ វាជាទង្វើ ឬសកម្មភាពដែលបន្តគាំទ្រឱ្យមានអ្នកសុំទានកើនឡើង ហើយពួកគេមិនព្រមចាកចេញពីជីវិតអនាថា និងមិនទទួលយកសេវាដែលផ្តល់ដោយស្ថាប័នរដ្ឋ និងអង្គការដៃគូ ជាពិសេស កុមារមិនទៅសាលារៀន និងបោះបង់ការសិក្សា ឬទទួលរងអំពើហិង្សាក្នុងរូបភាពផ្សេងៗ។

### ៤.៦.២. វិធានការចម្បង

ក្នុងន័យនេះ និងដើម្បីផ្លាស់ប្តូរផ្នត់គំនិតប្រជាជន, រាជរដ្ឋាភិបាលមានវិធានការចម្បង ដូចជា៖

- ផ្សព្វផ្សាយ អប់រំ និងណែនាំដល់សហគមន៍អំពីការលើកកម្ពស់សេចក្តីថ្លៃថ្នូរក្នុងការរស់នៅសំដៅកាត់បន្ថយភាពអសន្តិសុខ និងភាពឥតសណ្តាប់ធ្នាប់ ព្រមទាំងផលអវិជ្ជមានផ្សេងៗដែលបណ្តាលមកពីបញ្ហាជនអនាថា
- ណែនាំ និងផ្សព្វផ្សាយដល់សហគមន៍ក្នុងការផ្លាស់ប្តូរផ្នត់គំនិតដោយបញ្ឈប់ការឱ្យទានដល់ជនអនាថាប្រកបដោយគ្រោះថ្នាក់ ជំនួសដោយការជួយគាំទ្រតាមមធ្យោបាយផ្សេងៗ ដូចជាផ្តល់ឱកាសការងារ ឬបរិច្ចាគថវិកាទៅកន្លែងសំចតសុវត្ថិភាព និងមជ្ឈមណ្ឌលឯកទេសសង្គមកិច្ចរបស់រដ្ឋ អង្គការ និងសមាគម នានា ដែលគាំទ្រកុមារ និងគ្រួសាររបស់ពួកគេ
- ផ្សព្វផ្សាយលើកទឹកចិត្តឱ្យប្រជាជនយកចិត្តទុកដាក់ក្នុងការថែទាំសុខភាពផ្លូវចិត្ត និងចេះស្វែងរកសេវាប្រឹក្សាពីអ្នកជំនាញក្នុងសហគមន៍ ឬមូលដ្ឋានសុខាភិបាលសាធារណៈ
- លើកទឹកចិត្តសហគមន៍ផ្តល់កិច្ចសហការជាមួយអាជ្ញាធរពាក់ព័ន្ធក្នុងការជូនដំណឹងអំពីមុខសញ្ញា និងទីតាំងរបស់ជនអនាថាដើម្បីឱ្យប្រតិបត្តិករចុះអន្តរាគមន៍ទាន់ពេល។

## ៥. យន្តការជំរុញការអនុវត្តគោលនយោបាយ

ដើម្បីសម្រេចចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រខាងលើ, យន្តការជំរុញការអនុវត្តគោលនយោបាយស្តីពីការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា មានដូចខាងក្រោម៖

### ៥.១. ការអភិវឌ្ឍក្របខណ្ឌគតិយុត្ត

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយនេះ, ការរៀបចំក្របខណ្ឌគតិយុត្តមានសារៈសំខាន់សម្រាប់កំណត់អំពីវិធាននៃការអនុវត្តទិសដៅគោលនយោបាយដែលបានកំណត់, ការដោះស្រាយឫសគល់បញ្ហា "មេខ្យល់", ការគ្រប់គ្រង និងការរៀបចំមជ្ឈមណ្ឌលរដ្ឋ, ការកំណត់តួនាទី

និងភារកិច្ចក្រសួង-ស្ថាប័ន និងភារកិច្ចចាំបាច់ផ្សេងទៀត។ ក្នុងន័យនេះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងនីតិសម្បទា ត្រូវដឹកនាំ និងសហការជាមួយក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធ រៀបចំដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តចាំបាច់មួយចំនួន ដើម្បីឆ្លើយតបនឹងការដោះស្រាយបញ្ហាជនអនាថា ដូចខាងក្រោម៖

- រៀបចំអនុក្រឹត្យស្តីពីកិច្ចគាំពារ និងគ្រប់គ្រងជនអនាថា
- កន្លែងសំចតសុវត្ថិភាព និងមជ្ឈមណ្ឌលឯកទេសសង្គមកិច្ចរបស់រដ្ឋ អង្គការ សមាគម និងវិស័យឯកជន ត្រូវរៀបចំ និងកែសម្រួលនូវលិខិតបទដ្ឋានគតិយុត្ត ដោយត្រូវឆ្លងកាត់កិច្ចប្រជុំពិភាក្សាអន្តរក្រសួង និងការយល់ស្របពីគ្រប់ក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធ។
- រៀបចំ និងកែសម្រួលបទដ្ឋានគតិយុត្តស្តីពីក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់កម្លាំងសេវាសង្គមដែលអនុវត្តការងារដោះស្រាយបញ្ហាជនអនាថា ដោយមានបញ្ញត្តិនូវទណ្ឌកម្មវិន័យ ស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងបទប្បញ្ញត្តិជាធរមាន ពិសេសករណីមន្ត្រីអនុវត្តខាងលើប្រព្រឹត្តខុសនឹងក្រមសីលធម៌វិជ្ជាជីវៈនេះ។
- រៀបចំលិខិតបទដ្ឋានគតិយុត្តដែលកំណត់អំពីវិធានការរដ្ឋបាលចំពោះសកម្មភាពពាក់ព័ន្ធនឹងការរែអង្គាសថវិកាដែលគ្មានការអនុញ្ញាត។
- រៀបចំអន្តរាគមន៍ និងចាត់វិធានការផ្នែកច្បាប់ និងរដ្ឋបាលពាក់ព័ន្ធចំពោះសកម្មភាពពាក់ព័ន្ធនឹងការចងក្រង ឬប្រមូលផ្តុំជនអនាថាជាក្រុម (មេខ្យល់), ការជិះជាន់កេងប្រវ័ញ្ចកម្លាំងពលកម្ម ឬផ្លូវភេទ, ឬការប្រើអំពើហិង្សាលើកុមារ ស្ត្រី ជនមានពិការភាព និងមនុស្សវ័យចាស់ ក្នុងរូបភាពផ្សេងៗដែលជាកម្មវត្ថុនៃការរំលោភបំពានសិទ្ធិមនុស្ស។
- រៀបចំលិខិតគតិយុត្តដទៃទៀតសម្រាប់ដោះស្រាយបញ្ហាជនអនាថា តាមការចាំបាច់។

## ៥.២. យន្តការស្ថាប័ន និងយន្តការសម្របសម្រួលក្នុងការអនុវត្តគោលនយោបាយ

ដើម្បីជំរុញការអនុវត្តគោលនយោបាយស្តីពីការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថាប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល, ការចូលរួមផុសផុលពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានភាពចាំបាច់ ដើម្បីរៀបចំវិធានការល្អិតល្អន់ និងផែនការសកម្មភាពឱ្យបានច្បាស់លាស់ ម៉ត់ចត់ និងចំគោលដៅ។ ទន្ទឹមនេះ, យន្តការសម្របសម្រួលកិច្ចសហការរវាងក្រសួង-ស្ថាប័នគ្រប់កម្រិត និងភាគីពាក់ព័ន្ធក្នុងការអនុវត្តគោលនយោបាយនេះ ក៏មានភាពចាំបាច់ផងដែរ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលប្រគល់ភារកិច្ចដឹកនាំការអនុវត្តគោលនយោបាយស្តីពីការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយមានកិច្ចសហការពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ពិសេសរដ្ឋបាលរាជធានី-ខេត្ត ដែលជាប្រតិបត្តិករដោះស្រាយបញ្ហាជនអនាថាផ្ទាល់ តាមរយៈយន្តការសម្របសម្រួលដែលមានស្រាប់ ដោយមានគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា (គ.ជ.អ) និងអនុគណៈកម្មាធិការដោះស្រាយ

បញ្ហាជនអនាថា រាជធានី-ខេត្ត (អ.គ.អ) ដែល គ.ជ.អ និង អ.គ.អ អាចត្រូវបានកែសម្រួលតាមភាពចាំបាច់។

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានភារកិច្ច ដូចខាងក្រោម៖**

- ដឹកនាំ និងសម្របសម្រួលជាមួយគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំផែនការសកម្មភាព និងផែនការថវិកាជាក់លាក់ សម្រាប់រយៈពេល៣ឆ្នាំរំកិល ដើម្បីធានាប្រសិទ្ធភាព នៃការអនុវត្តវិធានការចម្បង ដែលបានកំណត់ក្នុងគោលនយោបាយនេះ ដោយកំណត់សកម្មភាពអាទិភាពជាក់លាក់ និងសូចនាករដែលវាស់វែងបាន ព្រមទាំងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំជូនក្រុមប្រឹក្សាជាតិគាំពារសង្គម។
- កែលម្អ និងពង្រឹងយន្តការសម្របសម្រួលនៃគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា (គ.ជ.អ) និងអនុគណៈកម្មាធិការដោះស្រាយបញ្ហាជនអនាថា រាជធានី-ខេត្ត (អ.គ.អ) ព្រមទាំងធ្វើការផ្សព្វផ្សាយឱ្យភាគីពាក់ព័ន្ធទាំងអស់ បានជ្រាបច្បាស់អំពីតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការ និងអនុគណៈកម្មាធិការនេះ។
- ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា (គ.ជ.អ) ជាប្រចាំ ដើម្បីជំរុញការអនុវត្តគោលនយោបាយ រួមទាំងការចូលរួមយ៉ាងសកម្មពីអនុគណៈកម្មាធិការដោះស្រាយបញ្ហាជនអនាថា រាជធានី-ខេត្ត (អ.គ.អ)។
- គ្រប់គ្រង ចាត់ចែង និងតាមដានការងារដោះស្រាយបញ្ហាជនអនាថា ដោយសហការជាមួយរដ្ឋបាលរាជធានី-ខេត្តដែលជាស្ថាប័នទទួលបន្ទុកការប្រមូលផ្តុំជនអនាថានៅតាមមូលដ្ឋានការគ្រប់គ្រងកន្លែងសំចតសុវត្ថិភាព និងសហការកំណត់អត្តសញ្ញាណបឋម។
- សហការជាមួយអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ក្នុងការរៀបចំយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ, ការផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្ត, និងការជំរុញការអនុវត្តវិធានការដែលមានវឌ្ឍនភាពយឺត ឬមិនមានវឌ្ឍនភាព។

## ៥.៣. ការបណ្តុះបណ្តាលធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ

### ៥.៣.១. ការបណ្តុះបណ្តាលធនធានមនុស្ស

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយនេះ ការបណ្តុះបណ្តាលធនធានមនុស្សត្រូវធ្វើឡើងនៅគ្រប់កម្រិត ដែលរួមមាន៖

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ការបណ្តុះបណ្តាលធនធានមនុស្សគ្រប់កម្រិត ទាំងកម្រិតគោលនយោបាយ និងកម្រិតប្រតិបត្តិ ដោយរៀបចំគ្រូបង្គោល និងឯកសារបណ្តុះបណ្តាលលម្អិតតាមកម្រិតនីមួយៗ ព្រមទាំងត្រូវផ្តល់ឯកសារបណ្តុះបណ្តាលទាំងនោះ ជូនស្ថាប័នពាក់ព័ន្ធគ្រប់កម្រិត។

- វគ្គបណ្តុះបណ្តាល និងឯកសារបណ្តុះបណ្តាលត្រូវរៀបចំឱ្យមានលក្ខណៈជាជំហានៗ សម្រាប់ភាពងាយយល់ដល់អ្នកអនុវត្តនៅគ្រប់កម្រិត ហើយមេរៀនគួរត្រូវបានរក្សាទុកនៅបណ្ណាសារកណ្តាលសម្រាប់ងាយស្រួលស្វែងរក និងទាញយកមកប្រើប្រាស់។
- អនុគណៈកម្មាធិការដោះស្រាយបញ្ហាជនអនាថា រាជធានី-ខេត្ត ត្រូវទទួលបានការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការអនុវត្តវិធានការ, ការរៀបចំផែនការសកម្មភាព, បច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងទិន្នន័យ, យន្តការកំណត់អត្តសញ្ញាណរបស់ជនអនាថា និងការគ្រប់គ្រងករណីជនអនាថាទៅតាមប្រភេទដែលបានកំណត់, វិធីសាស្ត្រក្នុងការសម្របសម្រួលផ្តល់ការគាំទ្រនានាដល់មន្ត្រីអនុវត្តនៅថ្នាក់ក្រោមជាតិគ្រប់កម្រិត ព្រមទាំងជាមួយដៃគូ និងវិស័យឯកជននានា។
- រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់កម្រិត, កម្លាំងសេវាសង្គមកិច្ច, មន្ត្រី និងបុគ្គលិកសង្គមកិច្ចគ្រប់ផ្នែក, និងបុគ្គលិកសង្គមកិច្ចរបស់អង្គការ សមាគមនានា និងវិស័យឯកជន ដែលទទួលបន្ទុកការងារនៅកន្លែងសំចតសុវត្ថិភាព និងមជ្ឈមណ្ឌលឯកទេសសង្គមកិច្ចនានា, ការងារបញ្ជូនបន្ត និងការងារដោះស្រាយបញ្ហាជនអនាថាដោយផ្ទាល់ផ្សេងទៀត ត្រូវទទួលបានការណែនាំ និងបណ្តុះបណ្តាលអំពីនីតិវិធី, ក្រមសីលធម៌វិជ្ជាជីវៈ, ជំនាញកំណត់អត្តសញ្ញាណ, ជំនាញគ្រប់គ្រងករណី, ជំនាញចិត្តសង្គម, ការប្រាស្រ័យទាក់ទង, សេវាថែទាំ និងព្យាបាល ព្រមទាំងបច្ចេកទេសពាក់ព័ន្ធនឹងការផ្តល់សេវាផ្សេងៗ ដូចជាការគាំទ្រការស្នាក់នៅតាមកន្លែងសំចតសុវត្ថិភាព, យន្តការគ្រប់គ្រង, ផែនការសមាហរណកម្ម, ការកត់ត្រាចងក្រងទិន្នន័យ, និងការប្រើប្រាស់ប្រព័ន្ធតាមដានឌីជីថល ក៏ដូចជាចំណេះដឹង លើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការធ្វើសមាហរណកម្មជនអនាថាទៅសហគមន៍។

### ៥.៣.២. ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តគោលនយោបាយស្តីពីការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា បានមកពថវិការដ្ឋ, ហិរញ្ញប្បទានពីកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍, វិស័យឯកជន, និងប្រភពស្របច្បាប់ផ្សេងទៀត តាមរយៈការកៀរគរទាំងធនធានហិរញ្ញវត្ថុ, បច្ចេកទេស, ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈផ្សេងៗ។

## ៥.៤. ការរៀបចំផែនការសកម្មភាពសម្រាប់ការអនុវត្តគោលនយោបាយ

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយនេះ, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវរៀបចំផែនការសកម្មភាព ៣ឆ្នាំ រំកិល ដោយមានការកំណត់សូចនាករសមិទ្ធកម្មគន្លឹះច្បាស់លាស់ ដែលអាចវាស់វែងបាន ដោយពិចារណាគ្រប់ទិដ្ឋភាព ផ្អែកលើការវិភាគស្ថានភាពជាក់ស្តែង ការពិគ្រោះយោបល់ និងកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធ ឱ្យបានទូលំទូលាយ ជាពិសេសរដ្ឋបាលរាជធានី-ខេត្ត។ ផែនការសកម្មភាព ៣ឆ្នាំ រំកិលនេះ ត្រូវឆ្លុះបញ្ចាំងពីចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាលក្នុងការបន្តថែរក្សាឧត្តមប្រយោជន៍ជាតិ, សណ្តាប់ធ្នាប់សាធារណៈ,

សោភ័ណភាព, សេចក្តីថ្លៃថ្នូរសង្គម, ព្រមទាំងរួមចំណែកដល់ការគាំពារសុខុមាលភាពជនអនាថា ប្រកបដោយប្រសិទ្ធភាព ដោយត្រូវឆ្លើយតបនឹងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ព្រមទាំងត្រូវអនុវត្តក្នុងក្របខណ្ឌកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលផងដែរ។

## ៦. ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីអនុវត្តគោលនយោបាយស្តីពីការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថា ឱ្យមានប្រសិទ្ធភាព ចាំបាច់ត្រូវមានយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ។ ទន្ទឹមនេះ ដោយគោលនយោបាយនេះជាឯកសាររស់ ដែលនឹងត្រូវបន្តពិនិត្យ និងវាយតម្លៃ ក៏ដូចជាផ្ទៀងផ្ទាត់នឹងស្ថានភាពជាក់ស្តែង និងបរិបទរបស់កម្ពុជា ជាប្រចាំ, គោលនយោបាយនេះនឹងត្រូវបានវាយតម្លៃកម្មវិបាក ក្នុងកម្រិតយុទ្ធសាស្ត្រ រៀងរាល់ ៣ឆ្នាំម្តង ដើម្បីពិនិត្យលើភាពជាប់ពាក់ព័ន្ធ ព្រមទាំងធ្វើការកែលម្អយុទ្ធសាស្ត្រ និងវិធានការចម្បង ឱ្យបានទាន់ពេល។ ក្នុងន័យនេះ រាជរដ្ឋាភិបាល ប្រគល់ភារកិច្ចការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយនេះ ជូនក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលមានអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម ជាសេនាធិការ ដោយត្រូវអនុវត្តភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ និងសម្របសម្រួលជាមួយគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ពិសេសក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីរៀបចំយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកម្មវិបាកក្នុងកម្រិតយុទ្ធសាស្ត្រ ដោយមានការកំណត់សូចនាករសមិទ្ធកម្មគន្លឹះ ដែលអាចវាស់វែងបាន និងក្របខណ្ឌពេលជាក់លាក់។
- តាមដាន និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រ និងវិធានការចម្បង ដែលបានដាក់ចេញក្នុងគោលនយោបាយនេះ និងសម្របសម្រួលជាមួយក្រសួង-ស្ថាប័នទទួលបន្ទុក ដើម្បីជំរុញការអនុវត្តវិធានការដែលមានវឌ្ឍនភាពយឺត ឬមិនមានវឌ្ឍនភាព។
- ទទួលរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីពិនិត្យ វាយតម្លៃ និងរាយការណ៍ជូនក្រុមប្រឹក្សាជាតិគាំពារសង្គម។
- តាមដាន និងត្រួតពិនិត្យការអនុវត្តយុទ្ធសាស្ត្រ និងវិធានការចម្បង និងស្នើកែសម្រួលជាប្រចាំ ដើម្បីឆ្លើយតបនឹងបរិការណ៍ជាក់ស្តែង ស្របតាមការវិវត្តរបស់សង្គមជាតិ ក្នុងន័យធានាឱ្យបាននូវវឌ្ឍនភាព សង្គតិភាព និងប្រសិទ្ធភាពការងារ។
- វាយតម្លៃកម្មវិបាកក្នុងកម្រិតយុទ្ធសាស្ត្រ រៀងរាល់ ៣ឆ្នាំម្តង ដោយតាមដាន និងត្រួតពិនិត្យផែនការសកម្មភាពរៀងរាល់ឆ្នាំ។

# ៧. សេចក្តីសន្និដ្ឋាន

គោលនយោបាយនេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្ត និងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាជនអនាថាដែលជាបញ្ហាសង្គមដ៏ស្មុគស្មាញ និងចាក់ស្រេះ។ តាមរយៈការដាក់ចេញនូវ**យុទ្ធសាស្ត្រសំខាន់ៗ និងយន្តការជំរុញការអនុវត្ត** រួមមានការរៀបចំប្រព័ន្ធអភិបាលកិច្ច, ការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យជនអនាថា និងយន្តការកំណត់អត្តសញ្ញាណជនអនាថា, ការពង្រឹងសេវាស្តារនីតិសម្បទានៅតាមមជ្ឈមណ្ឌលឯកទេសសង្គមកិច្ច, ការជំរុញយន្តការសមាហរណកម្មជនអនាថាទៅក្នុងសហគមន៍វិញ, យន្តការជំរុញជនអនាថាឱ្យទទួលបានអត្ថប្រយោជន៍ពីប្រព័ន្ធគាំពារសង្គម, ការអភិវឌ្ឍក្របខណ្ឌគតិយុត្ត, ព្រមទាំងយន្តការស្ថាប័ន និងយន្តការសម្របសម្រួលក្នុងការអនុវត្ត, គោលនយោបាយនេះនឹងក្លាយជាឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការចូលរួមលើកកម្ពស់សណ្តាប់ធ្នាប់សាធារណៈ សេចក្តីថ្លៃថ្នូរ និងជាពិសេស ផ្តល់ការគាំពារដល់ជនអនាថាដែលជាជនរងគ្រោះ ជនងាយរងគ្រោះ និងជនក្រីក្រ ប្រកបដោយប្រសិទ្ធភាព និងសមធម៌ ដោយឈរលើស្មារតី "**មិនបោះបង់ពលរដ្ឋណាម្នាក់**" ដើម្បីលើកស្ទួយជីវភាព និងសុខុមាលភាព ព្រមទាំងជំរុញការចាកចេញពីភាពក្រីក្រ។

ដើម្បីអនុវត្តគោលនយោបាយនេះឱ្យមានប្រសិទ្ធភាព ទាមទារឱ្យមានការចូលរួម គាំទ្រសហការពេញលេញពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ វិស័យឯកជនដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងភាគីពាក់ព័ន្ធ។ រាជរដ្ឋាភិបាលជឿជាក់យ៉ាងមុតមាំថា ក្រសួង-ស្ថាប័ន និងក្រុមការងារពាក់ព័ន្ធជាពហុវិស័យទាំងអស់រួមគ្នាសហការ ជំរុញ គាំទ្រ ផ្សព្វផ្សាយ និងអនុវត្តគោលនយោបាយស្តីពីការគ្រប់គ្រង និងការដោះស្រាយបញ្ហាជនអនាថានេះឱ្យសកម្ម មានភាពប្រទាក់ក្រឡា និងបំពេញឱ្យគ្នាទៅវិញទៅមក ប្រកបដោយប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់។

# ៨. សទ្ទានុក្រម

- **កន្លែងសំចតសុវត្ថិភាព** សំដៅលើកន្លែងដែលផ្តល់កន្លែងស្នាក់នៅបណ្តោះអាសន្នសម្រាប់ជនអនាថាដែលគ្រប់គ្រងដោយរដ្ឋបាលរាជធានី-ខេត្ត ដើម្បីកំណត់អត្តសញ្ញាណបឋម (ក្នុងរយៈពេលយ៉ាងយូរ ៧២ម៉ោង) មុននឹងបញ្ជូនបន្តទៅទទួលសេវាចាំបាច់នៅតាមមជ្ឈមណ្ឌលឯកទេសសង្គមកិច្ចផ្សេងៗ។
- **មជ្ឈមណ្ឌលឯកទេសសង្គមកិច្ច** សំដៅលើមជ្ឈមណ្ឌលដែលផ្តល់កន្លែងស្នាក់នៅ អាហារហូបចុក បណ្តុះបណ្តាលជំនាញខ្លីៗ និងបំណិនជីវិត និងសេវាឯកទេសដល់ជនអនាថា ដែលអនុវត្តដោយអ្នកអាជីពសង្គមកិច្ច និងអ្នកអាជីពសង្គមកិច្ចរង មានចំណេះដឹងនិងជំនាញ និងក្រមសីលធម៌វិជ្ជាជីវៈ។
- **ការគ្រប់គ្រងករណី** សំដៅដល់ដំណើរការគ្រប់គ្រងព័ត៌មាន ស្ថានភាព បញ្ហាប្រឈម និងតម្រូវការរបស់ជនអនាថាចាប់ពីការប្រមូលផ្តុំជនអនាថាមកដល់កន្លែងសំចតសុវត្ថិភាព រហូតដល់ការអនុវត្តយន្តការសមាហរណកម្មជនអនាថាទៅក្នុងសហគមន៍ ដែលដំណើរការមានដូចខាងក្រោម៖

    ១. ការទទួល និងកំណត់អត្តសញ្ញាណជនអនាថា

    ២. ការប៉ាន់ប្រមាណ (បឋម និងគ្រប់ជ្រុងជ្រោយ) ជនអនាថា និងគ្រួសារ រួមទាំងការរៀបចំសន្និសីទករណីជនអនាថា

    ៣. ការរៀបចំផែនការករណីជនអនាថា

    ៤. ការអនុវត្តផែនការករណីជនអនាថា

    ៥. ការតាមដាន និងត្រួតពិនិត្យផែនការករណីជនអនាថា និង

    ៦. ការបិទករណីជនអនាថា។

- **កម្លាំងសេវាសង្គម** សំដៅដល់ជនទាំងឡាយណា ទាំងមន្ត្រីរាជការ បុគ្គលិកសមាគម និងអង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងរូបវន្តបុគ្គល ទោះជាអ្នកអាជីព អ្នកអាជីពរង ឬអ្នកមានជំនាញច្បាស់លាស់ផ្នែកការងារសង្គមកិច្ច ដោយយកកម្រៃ ឬមិនយកកម្រៃ ធ្វើការដើម្បីធានាបាននូវការអភិវឌ្ឍសុខុមាលភាពរបស់អតិថិជន។ កម្លាំងសេវាសង្គមត្រូវមានគុណតម្លៃស្នូលរបស់ខ្លួន ៣យ៉ាង រួមមានការគោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស យុត្តិធម៌សង្គម និងសុចរិតភាពវិជ្ជាជីវៈ។ កម្លាំងសេវាសង្គមមានប្រភេទដូចខាងក្រោម៖
    - **អ្នកអាជីពសង្គមកិច្ច៖** ជាអ្នកដែលមានជំនាញវិជ្ជាជីវៈក្នុងការផ្តល់សេវាសង្គមកិច្ចទាំងមូល។ អ្នកអាជីពសង្គមកិច្ចត្រូវមានសញ្ញាបត្រសង្គមកិច្ចដោយមានការទទួលស្គាល់ពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងមានអាជ្ញាបណ្ណទទួលស្គាល់ដោយស្ថាប័នទទួលបន្ទុកសង្គមកិច្ច។
    - **អ្នកអាជីពសង្គមកិច្ចរង៖** ជាអ្នកដែលធ្វើការអមជាមួយ ឬជួយការងាររបស់អ្នកអាជីព-សង្គមកិច្ច។ អ្នកអាជីពសង្គមកិច្ចរង ត្រូវបានបណ្តុះបណ្តាលឱ្យបំពេញមុខងារជាក់លាក់មួយចំនួន ប៉ុន្តែមិនតម្រូវឱ្យមានការបញ្ជាក់ ឬផ្តល់អាជ្ញាបណ្ណទទួលស្គាល់ដោយស្ថាប័នជំនាញ

សាធារណៈផ្នែកសង្គមកិច្ច ដូចអ្នកអាជីពសង្គមកិច្ចនោះទេ តែក្នុងមុខងារខ្លះតម្រូវឱ្យមានសញ្ញាបត្រឯកទេស។

- **អ្នកសង្គមកិច្ចបឋម៖** ជាអ្នកដែលកំពុងធ្វើការក្នុងផ្នែកសង្គមកិច្ច ឬជាអ្នកស្ម័គ្រចិត្ត ដែលភាគច្រើនធ្វើការនៅសហគមន៍ ដោយមានការជួយគាំទ្រផ្នែកបច្ចេកទេសពីអ្នកអាជីពសង្គមកិច្ច ឬអ្នកអាជីពសង្គមកិច្ចរង។ អ្នកសង្គមកិច្ចបឋម បម្រើដល់តម្រូវការរបស់អតិថិជន រួមទាំងកុមារ និងគ្រួសារ ជាពិសេសនៅក្នុងកន្លែងដែលប្រព័ន្ធសុខុមាលភាពសង្គមមិនទាន់បានបង្កើត ឬមានកម្រិតនៅឡើយ។
- **អ្នកសង្គមកិច្ចសម្ព័ន្ធ៖** ជាអ្នកដែលផ្តល់សេវាសង្គម ប៉ុន្តែត្រូវបានផ្សារភ្ជាប់ជាមួយនឹងវិស័យផ្សេងទៀតដូចជា ការអប់រំ សុខភាព ឬយុត្តិធម៌។ ឧទាហរណ៍ រួមមាន គិលានុបដ្ឋាយិកា មេធាវី វេជ្ជបណ្ឌិត និងគ្រូបង្រៀន និងអ្នកផ្សេងទៀត។ បុគ្គលិកសម្ព័ន្ធសង្គមកិច្ចអនុវត្តមុខងារជាច្រើន ដែលធ្វើឱ្យប្រសើរឡើងដល់ការគាំទ្រ ឬសម្របសម្រួលមុខងារដែលអនុវត្តដោយកម្លាំងសេវាសង្គមផ្សេងទៀត។